# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូតព្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់


| *ផ្នែកអក្សរសាស្ត្រ* | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ក្រុមជំនុំលទ្ធិទំនៀមខ្មែរ . . . . | ប្រកាសតែងប្រកួតរឿងបុណ្យភ្ជុំបិណ្ឌ . . . | ៦០៧ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . | សេចក្ដីពន្យល់អំពីពាក្យខ្មែរខ្លះ ក្នុងសេចក្ដីរាយការជាភាសាចិន ក្នុងសតវត្សរ៍ ទី ១៣ (តាមអត្ថាធិប្បាយរបស់លោកសឺដែស) . . | ៦០៩ |
| លោក ហាន់-យេង . . . . . . | រឿងកំពូលកំសត់ (តមកនឹងចប់) . . . . . | ៦២៩ |
| មេបុនបណ្ណានុរក្ស ប៊ូ-ប៊ូ . . . . | ដំឡើងសិល្បសាស្ត្រ (តមកនឹងចប់) . . . . | ៦៣៨ |
| *ផ្នែកសាសនា* | | |
| លោកព្រះចៅអធិការ ឯក-ញឹម . | ធម្មបទភាសិត (តមកនឹងចប់) . . . . . . | ៦៤៨ |
| ពុទ្ធសាសនបណ្ឌិត្យ . . . . | ពិធីប្រគល់ព្រះរាជក្រឹត្យ . . . . . . . . . | ៦៦០ |
| " " | ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យបានទទួល ព្រះរាជទានគ្រឿងឥស្សរិយយស . . . . . . | ៦៦៣ |
| ដំណឹងអំពីក្រសួងធម្មការ . . . | សេចក្ដីរាយការសង្ខេបនៃមហាសង្ឃសន្និបាត នៅវត្តព្រះកែវ និងវត្តសារាវ័ន . . . . . . | ៦៦៥ |
| " " | អំពីតាំងចៅអធិការថ្មី . . . . . . . . . | ៦៦៨ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . | ឯកភាគនៃមិលិន្ទបញ្ហា (តមក) . . . . . | ៦៧០ |

# KĂMPUCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Luong Nibandhamantri NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Preah kru Paññalikhito KAO-SIM, Surveillant général de l'École Supérieure de Pāli.

## *TABLE DES MATIÈRES*

**Partie littéraire :**

| | | Pages |
|---|---|---|
| Commission des mœurs et coutumes cambodgiennes | Concours littéraires sur la fête de P'chŏm-Bĕn . . . . . . . . | 617 |
| Luong Niponmontrei Nhok-Thèm . . . . . . | Explication de quelques mots cambodgiens contenus dans les rapports chin:ais du 13e siècle (d'après les travaux de M. Cœdès) | 619 |
| Monsieur Han-Yéng. . . . | Kămpul kămsăt, roman (suite et fin) | 628 |
| K'ŭn Pannanŭrak Bou-Po | Dĭmlăi sĕlpăsas (suite et fin) . . | 638 |

**Partie religieuse :**

| | | |
|---|---|---|
| Vénérable Chau At'ikar Ek-Nhim . . . . . . | T'ĕammăbăt p'easĕt (suite et fin). . | 648 |
| Institut Bouddhique . . . | Compte-rendu de la remise de titres honorifiques aux membres du personnel de l'Institut Bouddhique . . . . . . . . . . . . . . | 660 |
| " " | Compte-rendu de la remise de décorations cambodgiennes aux membres du personnel de l'Institut Bouddhique et du Musée A. Sarraut . . . . . . . . . . . | 663 |
| Communiqué du Département des Cultes . . . | Compte-rendu de la réunion des chefs de diocèses à Vĕat Prĕah Kèv et à Vĕat Saravĕan . . . . . . . | 665 |
| " " | Nominations de nouveaux Chau At'ikar . . . . . . . . . . . | 668 |
| Luong Niponmontrei Nhok-Thèm . . . . . . . | Ekabhaga-Milindapañha (suite) . . . | 670 |

# ជូនពរសព្ទសាធុការចូលឆ្នាំថ្មី

## គ្រិស្តសករាជ ១៩៤៩

នៅឱកាសចូលឆ្នាំថ្មីនៃជាតិបារាំង-ខ្មែរ ដែលរាជការទើបបានកែប្រែថ្មី ចាប់តាំងពីថ្ងៃ ១ យ៉ាំងវីយេរគ្រិស្តសករាជ ១៩៤៩ ជាដើមទៅ ដើម្បីគម្រូទៅតាមបែបលោកនិយម នោះកម្ពុជសុរិយាសូមជូនពរសព្ទសាធុការដោយស្មោះស្ម័គ្រចំពោះដល់អស់លោក-អ្នកជាវទស្សនាវដ្ដី កម្ពុជសុរិយាគ្រប់រូប ព្រមទាំងខេមរជាតិក្នុងកម្ពុជរដ្ឋ-សហរដ្ឋឥណ្ឌូចិន-មហានគរបារាំងសែស សូមឲ្យបានប្រកបដោយពរ ៤ ប្រការ គឺ : អាយុ វណ្ណៈ សុខៈ ពលៈ គ្រប់ទិវារាត្រីកុំបីឃ្លាតឡើយ ។

# ប្រកាសតែងប្រកួតរឿងបុណ្យភ្ជុំបិណ្ឌ

ក្រុមជំនុំលទ្ធិទំនៀមខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ សូមប្រកាសដល់អស់លោក-អ្នកចេះដឹងទាំងឡាយសូមជ្រាប ។

ដ្បិតក្រុមនេះ ត្រូវការចង់ដឹងពីរបៀបធ្វើបុណ្យភ្ជុំបិណ្ឌ តាមទំនៀមទម្លាប់ដែលគេធ្វើនៅក្នុងខែត្រ-ស្រុកផ្សេងៗ ក្នុងនគរកម្ពុជានេះ ជាមានរបៀបផ្សេងគ្នាដូចម្ដេចខ្លះ?

ហេតុនេះសូមលោកអ្នកចេះដឹងទាំងឡាយ មេត្តាតែងរឿងនោះ តាមរបៀបដែលធ្លាប់ធ្វើក្នុងស្រុករបស់ខ្លួនមានក៏ស្តុការ ទំនងរបៀបដូចម្ដេចខ្លះសុំតែងឲ្យបានពិស្ដារល្អិតល្អសព្វគ្រប់ រៀងតាំងពីដើមរហូតដល់

ចប់ កុំឲ្យមានខ្វះចន្លោះឲ្យសោះ តាំងសូមឲ្យប្រាប់ថា របៀបពិធីបុណ្យនេះធ្វើតាមគម្ពីរ-គម្រាអ្វីខ្លះឲ្យច្បាស់លាស់ផង ឬបើមានពិធី-កិច្ចអ្វីទៀតរួមជាមួយពិធីបុណ្យនេះក៏សូមអធិប្បាយផង ហើយផ្ញើទៅឲ្យក្រុមជំនុំដូចមានខាងលើឲ្យបានមុនថ្ងៃ ១៥ កើតខែផល្គុណ ។

ក្រុមជំនុំទទួលហើយ នឹងពិនិត្យមើល ការឆ្លើយរបស់លោក-អ្នកណាដែលត្រឹមត្រូវល្អ នឹងជូនជារង្វាន់តាមសមគួរ ។ រង្វាន់នោះមាន ៣ ថ្នាក់ គឺរង្វាន់លេខ ១ លេខ ២ លេខ ៣ តាមលំដាប់ដែលល្អអាក្រក់ជាងគ្នា ហើយនឹងមានចុះដំណឹងផ្សាយអំពីឈ្មោះអ្នកដែលបានរង្វាន់នេះផង ។ រឿងដែលជូនទៅនោះនឹងរក្សាទុកជាសម្បត្តិនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ជាប្រយោជន៍ដល់អ្នកសិក្សាទាំងឡាយតទៅ ។ -

ក្រុមជំនុំមានសេចក្ដីសង្ឃឹមជាបំផុតថា អស់លោក-អ្នកចេះដឹងទាំងឡាយនឹងជាមេត្តាឈឺឆ្អាលដែលឲ្យបានរៀបរាយល្អដូចបានសុំមក ។

ក្រុមជំនុំទំនៀមខ្មែរ

# សេចក្ដីអធិប្បាយ

ពន្យល់អំពីពាក្យខ្មែរខ្លះ ក្នុងសេចក្ដីរាយការណ៍ភាសាចិនរបស់ចៅ - តា - កួន

## ហ្លួងធិពន្ធមន្ត្រី ញ៉ុក - ថែម

ស្រង់ទីនាំថែចេញពីទស្សនាវដ្ដីរបស់សាលាបារាំងសែស

ចុងបូព៌ាប្រទេស (BEFEO., XVIII, p.4) (១)

---

រឿងរ៉ាវរបស់អ្នកដំណើរឈ្មោះ ចៅ-តា កួន ដែលចូលមកមើលស្រុកខ្មែរ ក្នុងឆ្នាំ ១២៩៦ នោះមានជាប់ពាក្យខ្មែរជាច្រើន ក្នុងសេចក្ដីកត់ត្រាជាភាសាចិន ។ លោកអាយម៉ូនញេ៉រ និងលោកហ្វី-ណូត៍បាន ធ្វើសេចក្ដីពន្យល់ពាក្យខ្មែរបន្ថែម ក្នុងសេចក្ដីប្រែរបស់លោកប៉េល្លីយោត៍ ។ ក្នុងទីនេះ លោកសឺដេសចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានពោលបំពេញលើសេចក្ដីអធិប្បាយទាំងនោះជាថ្មីឡើងទៀតខ្លះ ដូចមានតទៅនេះ:

### ត្រង់ពាក្យ : ប-ណាន, ហ្វូ-ឈៀន, កន-ប៉ាង

អំពីមាត់ពាមសមុទ្រ គេអាចទៅតាមផ្លូវទឹកបានស្រួលតាមទិសខាងជើង ក្នុងវេលា ១៥ ថ្ងៃ, ដល់ប្រទេស ១ ហៅថា ប-ណាន

---

១. សេចក្ដីរាយការណ៍របស់ ចៅ - តា - កួន នេះយើងបានប្រែចុះផ្សាយក្នុងកម្ពុជសុរិយា ខាង:និងឆ្នាំៗ នេះរួចមកហើយ ហៅថា "រឿងអង្គរក្នុងសតវត្សរ៍ទី ១៣" ទើបគួរចុះរឿងនេះ នៅទំព័រកាសមុខជាប់ឆ្នាំ ៗ នេះ ។

ដែលមានកងការខ្មែរកាន់កាប់ក្បៀ ។ អំពី តា-ណាន គេអាចចុះទូកខ្នាតតូច ហើយធ្វើដំណើរតាមខ្សែទឹក ១០ថ្ងៃឆ្លងកាត់ទៅប៉ាន-លូ-ឈៀន (ភូមិព្រះពុទ្ធ) ហើយឆ្លងសមុទ្រទឹកសាបទៅ ទើបដល់ទៅកាន់-ប៉ាង នៅចម្ងាយ ៥០ លី ពីទីក្រុង" ។

លោកអាយម៉ូញេរបានបន្ថែមប្រាប់ថា តា-ណាន នៅកំពង់ឆ្នាំង, ប៉ុន្តែលោកប៉េល្លិយោត៍យល់សមខាង ភ្នំពេញជាង ។ លោកនេះពោលថា "មិនត្រូវភ្លេចថា គេធ្វើដំណើរជើងទឹក ១៥ ថ្ងៃ ទើបដល់ តា-ណាន ហើយនៅ ១០ ថ្ងៃទៀត ទើបដល់ផ្លូវចូលទៅស្ទឹងសៀមរាប; កំពង់ឆ្នាំង ជិតទៅខាងចុងដំណើរពេក មួយទៀតពិបាកនឹងកំណត់ភូមិ ឬស្រុក ទាំងពីរ គឺ ប៉ាន លូ-ឈៀន និងហូ-ឈៀន នៅចន្លោះកំពង់ឆ្នាំង នឹងផ្លូវដែលចូលទៅទន្លេសាប ប្រសិនបើដៅយក តា-ណាន នៅមាត់ទន្លេបួនមុខ ប៉ាន-លូ-ឈៀន អាចជាស្រុកកំពង់ឆ្នាំង ហូ-ឈៀន (ភូមិព្រះពុទ្ធ) ប្រហែលនៅត្រឹមបរិបូណ៌ ដ្បិតទីនោះធ្លាប់ជាទីមានព្រះពុទ្ធសាសនាចំរើនរុងរឿងមកគួរសមដែរ" ។

តែលោកសឺដេសយល់ថា តា-ណាន ប្រាកដជានៅក្នុងតំបន់កំពង់ឆ្នាំង ព្រោះមានសូរសំនៀងប្រហែលគ្នា ហើយប្រហែលជា ចៀវ-តា-កួន ចេញមកពីស្រុកចិនតាមផ្លូវខ្យល់មូស្សុងទិសឦសាន ។ ហេតុនេះ ចៀវ-តាកួនចូលមកក្នុងទន្លេ ក្នុងពេលស្រក ដោយ

ហេតុទឹកសម្រកនេះហើយបានជាមិនបាច់ផ្លាស់ទូកនៅភ្នំពេញ "បើទូកខ្នាតតូច" ព្រោះទូកធំៗ អាចចេញចូលតាមដៃទន្លេសាបបានគ្រប់ផ្លូវៗ ការដែលផ្លាស់ទូកៈនៅកំពង់ឆ្នាំង ព្រោះគោងចូលតាមប្រឡាយទឹកគោង ប្រើទូកតូចទើបទៅបាន ។ ក្នុងពេលដែលចៀវ-តាក្វាន់ធ្វើដំណើរពីមាត់ពាមសមុទ្ររហូតមកដល់ទន្លេសាបនោះខ្សែទឹកមិនហូរខ្លាំងទេ ទើបមិនបាច់ឲ្យលឿនធ្លាប់រាដំណើររហ័សមាត់ពាមសមុទ្រទឹងកំពង់ឆ្នាំង ជារយៈវេលា ១៥ ថ្ងៃ ហើយ ចៀវ-តាក្វាន់ ដើរផ្លូវដល់ ១០ ថ្ងៃទៀត ទើបដល់កំពង់ចូលទៅស៊ីងអង្គរ ។ ត្រង់ពាក្យថា "ទន្លេសមុទ្រទឹកសាប" មិនមែនអធិប្បាយថា ពួកដើងបែរដែលនាំអ្នកដំណើរជាតិចិនសំដៅទៅកំពង់ទន្លេសាបហូរចូលទៅតាមស៊ឹងអង្គរទេ គឺប្រាកដជាទូកទៅតាមផ្លូវដែលធ្លាប់ប្រើញឹកញយនោះឯង ហើយសសៀរទៅឆ្នេរទន្លេខាងត្បូងរហូតដល់ពោធិ៍សាត់ មុនច្នៃកាត់ទទឹងទន្លេសាប រួចកាត់សំដៅទៅច្រាំងភ្នំក្រោម ដូច្នេះទើបឃើញថា ចា-ណាន នៅត្រឹមកំពង់ឆ្នាំង, ប៉ាន-លូ-ឈៀន ទឹង ហ៊ូ-ឈៀន មិនមែននៅចន្លោះត្រង់តំបន់ថយមកក្រោយ ទឹងកំពង់ទន្លេសាបទេ គឺនៅត្រង់មាត់ទន្លេសាបខាងត្បូង ។ ដូច្នេះ ទើបខ្ញុំ (លោក សឺដេស) ដៅយកហ៊ូ-ឈៀន "ភូមិព្រះពុទ្ធ" នៅពោធិ៍សាត់ ដែលមានឈ្មោះប្រាកដមក គេតែងដឹងថា ស្រុកពោធិ៍សាត់ (ពោធិសត្វ) ។

កាន់-ប៉ាំង ប្រាកដជាត្រូវនឹងពាក្យថា កំពង់ លោកប៉េល្លិ-យោត ពន្យល់ពាក្យនេះថា គេអាចប្រើសំដៅយកតំបន់ដែលពិតប្រាកដមួយ ៗ ប៉ុន្តែពាក្យនេះមិនជាការចំឡែកទេ ព្រោះទម្លាប់និយាយភាសាខ្មែរ ពីសម័យទៀត — តគ្នារហូតមកដល់ឥឡូវនេះ មិនទាន់ប្រែប្រួលប៉ុន្មានទេ ដូចជាទម្លាប់និយាយសព្វថ្ងៃនេះ បើលោកសួរគេដែលចេញពីទីក្រុងទៅកំពង់ហ្លួង ថា "ទៅណា?" គេឆ្លើយថា "ទៅកំពង់ហ្លួង" ដូច្នេះ ក្នុង ១០ មានតែ ១ ទេ ច្រើនតែនិយាយថា បើអ្នកសួរគេថា "ទៅណា" គេឆ្លើយកំបុតៗថា "ទៅកំពង់" ។ ពាក្យថា កំពង់ ដែលអ្នកដំណើរចិនបានឡើងទៅនោះ ប្រាកដជាអ្នកបកប្រែភាសាសួរពួកជនខ្មែរក្នុងស្រុកដែលទូកដល់កំពង់ ពួកអ្នកខ្មែរក៏ឆ្លើយខ្លីៗថា "កំពង់" ទៀត - ពួកចិនក៏ចាប់យកពាក្យសាធារណនាម ត្រឡប់ជាអសាធារណនាមទៅវិញ (ដោយសំគាល់ថាជាឈ្មោះតំបន់) ។

## ត្រង់ពាក្យ: អ៊ាន-ទិង ប៉ា-ធា

"ចំណែកអ្នកទើបមកដល់ថ្មីស្លៀកសំពត់ជរទាំងពីរជុំ" ដូចអ៊ាន-ទិង-ប៉ាធា តែចិនទាំងនេះមិនត្រូវគេប្តឹងប្តល់ទេ ។ អ៊ាន-ទិង ប៉ាធា គឺអ្នកមិនស្គាល់ទំនៀមគេ" ។

'ផាន់-ទិន, លោកហ៊ុយណ្ហ៍អធិប្បាយថា ត្រូវនឹងពាក្យថា មិនគង់ (មិនដឹង) ពាក្យនេះគេប្រើសម្រាប់ច្បាប់ផង ឯពាក្យពីរម៉ាត់ទៀត គឺប៉ា-ផា ត្រូវនឹងភាសា ។

ឯពាក្យថា "ភាសា" នេះមិនមែនសំដៅសេចក្ដីត្រឹម "សំដី" ប៉ុណ្ណោះទេ គឺគាប់ប្រែថា របៀប, វិធី, សេចក្ដីប្រព្រឹត្តិ" ។ ពាក្យនេះនៅមានប្រើប្រាស់ក្នុងភាសាសៀម ដូចពាក្យថា "ភាសាជេក: គឺរបៀបបុគ្គលរបស់ក្មេង" "មៃរូប៉កភាសា: គឺមិនដឹងអ្វីឡើយ" សំនួនបែបនេះត្រូវនឹងពាក្យដែលពៀរ-តាគួនចាប់យកមកនិយាយនុ៎ះឯង ។

## ត្រង់ពាក្យ: ស៊ឺ-ឡា-ទី (Sseu-la-ti)

"ពួកមន្ត្រីមានច្បាប់ប្រើក្លស់មាស ហៅថា ប៉ា-ទ័ង ឬ ផាន់-ទិន, ពួកដែលប្រើក្លស់ប្រាក់ហៅថា "ស៊ឺ-ឡា-ទី" ។

ពាក្យ "ប៉ា-ទ័ង" ប្រហែលនឹងពាក្យបារំកថា 'ម្រគាញ ឬម្រេតង" ។ ចំណែកឯ ស៊ឺ-ឡា-ទី នោះខ្ញុំជឿថា ត្រូវនឹងពាក្យសំស្រ្កឹត: ស្រេឞ្ឋិន ពាក្យនេះមាននៅក្នុងសិលាចារិកលៃ ។

សូរសំឡេងពាក្យចិន និងសំស្រ្កឹត: ស៊ឺ-ឡា-ទី និងស្រេឞ្ឋិន-ប្រហែលគ្នា ជិតគ្នាគ្រាន់ប្រើ ។ ឯពាក្យក្រោយនេះ ខ្ញុំមិនជឿថា សំដៅយក "អ្នកជំនួញ" ឲមកទេ ។ ពៀរ-តាគួនគង់ចង់បង្ហាញពី

ជាន់ថ្នាក់របស់ពួកនាម៉ឺនមន្ត្រីខ្ពស់-ទាបចំពួកខ្លះ ហើយពាក្យថា គ្រប្ទិននេះក៏ប៉ុនគ្នានឹងពាក្យថា ចៅគ្រប្ទៈ (នាយកនៃវណ្ណៈ គឺពួកដែលមានទៅក្នុងតារាងប្រាសាទតាកែវនោះឯង ។

## ត្រង់ពាក្យៈ ជូ—គូ

### "ពួកលោកសង្ឃគេហៅថា ជូ-គូ"

ពាក្យនេះ លោកហ្វីណូតថា ប្រហែលជាត្រូវនឹងពាក្យសៀម ជា "ចៅគូ" ដែលប្រែថា គ្រូ-គ្រូ ។

ពាក្យ "ចៅគូ" នេះគេប្រើនិយាយសំដៅយកលោកសង្ឃក្នុងពុទ្ធសាសនា ក្នុងភាសាសៀមបុរាណ តាមដែលពួកអ្នកដំណើរក្នុងសតវត្សទី ១៧ បានពោលទុកមក ទើបនឹងសេចក្តីជាភាសាសៀមបុរាណ. ពាក្យនេះជាពាក្យសៀមសុទ្ធមិនមែនគ្រាន់តែប្រហែលទេ ។

ឯពាក្យថា គូ នោះ មិនមែនចេញមកពីពាក្យថា គ្រូ នោះទេ គឺពាក្យនេះជាសព្វនាម បឋមបុរស ហេតុនេះ ពាក្យថា "ចៅ" ម្ចាស់ ចៅហ្វាយ "គូ"អញ, ចៅគូ ម្ចាស់អញ ត្រូវនឹងពាក្យក្នុងសិលាចារឹកខ្មែរ ជា "កម្រតេងអញ" អញ ជាសព្វនាមបឋមបុរស[1] (Monseigneur) ។

---

១. ក្រៅពីពាក្យថា អ្នកយេង (អ្នកយើង) ដែលប្រើសំដៅយកលោកសង្ឃ មានក្នុងសិលាចារឹកនគរវត្តផង (Aymonier, Cambodge, III, p. 286).

ទៅចុងសតវត្សរ៍ ១៣ លោកសង្ឃពុទ្ធសាសនាបានតាំងឡើង ហើយក្នុងស្រុកខ្មែរ ដោយនិយមប្រើតាមពាក្យថៃ ។

## ត្រង់ពាក្យៈ បេន-កៀ-ឡាន

"ពួកស្រីដែលធ្វើការបម្រើនៅក្នុងវាំង គេហៅថា បេន - កៀ-ឡាន" ។ អធិប្បាយៈ "លោកកាបាតុនយល់ថា ស្រីង្គារៈ គឺស្រីក្នុងរាជ-សំណាក់; លោកអាយម៉ូញេ ថាសំដៅយក យ៉ាំងៈ គឺព្រះយ៉ាំងៈសួច ហើយច្រើនតែជាវាំងផង" ។

ពាក្យដែលលោកកាបាតុនពោលនេះសមណាស់ ពាក្យជាអក្សរចិននេះ ច្បាស់ជាចេញមកពីពាក្យសំស្ក្រឹតថា គ្រឹង្គារ ។ ពាក្យនេះតាមសព្ទដើមប្រែថា "គ្រឿងប្រដាប់ទីងសេចក្តីស្នេហា" យកមកប្រើក្នុងភាសាខ្មែរច្រើនសំដៅយក "ស្រីរូបល្អ" ចំពោះក្នុងរាជសំណាក់បានដល់ពួកស្រីព្រះស្នំ ឬស្ត្រីបរិវាររបស់មហាក្សត្រ ។ មានឧទាហរណ៍ដូចក្នុងសិលាចារិកអង្គរវត្ត ក្នុងឆ្នាំ ១៥៧៩ (Nº 6 B របស់លោកអាយម៉ូញេ Cambodge, III, p. 292) ដូច្នេះ "សូមឲ្យពួកទេវតាមកប្រជុំគ្នាជួយទំនុកបំរុងព្រះមហាក្សត្រ (ជាមហាឧបាសក) ព្រះរាជទេវី, ព្រះរាជបុត្រ ព្រះរាជមាតា, ពួកស្ត្រីជាបរិវារ (គ្រឹង្គារបរិវារ) ពួកត្រកូលព្រាហ្មណ៍, ពួកមន្ត្រី, ជាដើម ..." ។

# ត្រង់ពាក្យៈ បេ – ខ្មៃ

" ឪពុកធំខាងម្ដាយ ហៅថា បេ-ខ្មៃ ប្ដីរបស់ម្ដាយធំក៏ហៅថា បេ-ខ្មៃ ដែរ" ។

ពាក្យនេះប្រាកដជាត្រូវនឹងពាក្យ "ខ្មៃ" ដែលក្លាយយារមកជា ប្រើនត មាននៅក្នុងសិលាចារឹកនគរវត្ត នៃឆ្នាំ ១៧០១ (Nº 39 B, Aymonier, Cambodge., p. 309) នោះមាននិយាយពីមន្ត្រីម្នាក់បានទទួលឆ្លាជាគោសាថា: "លុះបានជាគោសាសោតបួស្ស ២ គ្គង បំបួស្ស កូនក្មួយបំបួសខ្មៃ ទុកកូនធម៌ជាសំម៉ោរ៉េអត្ត" ។ មានសេចក្ដីក្នុងចារឹក ១ ទៀតនៃឆ្នាំ ១៧៤៧ (nº 41 B. de Aymonier, iluid., P. 310) ថា: "មានឧកញ៉ាម្នាក់ចិញ្ចឹមក្មួយបុត្របុត្រព្រះពាន បំបួសបួមទារស្រីគ្នាគេសរ ជាប្រពន្ធ ទុកនាងកិម ជាខ្មៃ ទុកក្មួយស្រី ២ នាក់បួសជានាងជី . . ." ។ ក្នុងសេចក្ដីចារឹកទី ១ លោកអាយម៉ូនញេរប្រែពាក្យ "ខ្មៃ" ថា "កូនប្រសាប្រុស" ហើយក្នុងសេចក្ដីចារឹកទី ២ ប្រែថា "កូនប្រសាស្រី" ខ្ញុំមិនទាន់ទុកចិត្តនឹងពាក្យប្រែនេះទេ ដ្បិតពាក្យថា "កូនប្រសា" ដែលគេប្រើនិយាយសព្វថ្ងៃនេះ សឹងមានក្នុងវិជ្ជាចារឹកតាំងពីខាងដើមសតវត្សរ៍ទី ១៦ មកហើយ ។ ខ្ញុំជឿថាពាក្យថា "ខ្មៃ" ជារូបសព្ទបុរាណ ១ ឬជាពាក្យដែលត្រូវនឹងពាក្យថា "ថ្លៃ" ដែលប្រើសព្វថ្ងៃនេះសំដៅយក "បងថ្លៃប្អូនថ្លៃ" ពាក្យនេះគេអាចសំគាល់បានថា ឪពុកធំខាងម្ដាយ

និងប្តីរបស់ម្ចាស់ម៉ឺងខាងអាពុកនោះ ចៀវ-តាកួនគាំងចិត្តប្រើពាក្យ "បេថ្ងៃ" សំដៅយកជនទាំងពីរ ត្រូវជា "បងថ្លៃ" របស់អាពុក ។

## ត្រង់ពាក្យៈ ង៉ៃ-ឡាន

"នៅខែទី ៨ មាន (បុណ្យប្រចាំខែ) ង៉ៃ-ឡាន ង៉ៃ-ឡានគឺរាំល្ខោន" ។

ពាក្យខ្មែរមួយម៉ាត់នេះប្រែថារាំ (danser) សូម្បីក្នុងវិជ្ជាចារឹកក៏ប្រើដូចជាពាក្យខ្មែរថ្មីនេះដែរ ។ ចៀវ-តាកួនគង់បានឃើញគេរាំល្ខោនក្នុងពេលនោះផង ។

## ត្រង់ពាក្យៈ ប៉ាវ — លេង — គិរ

"គេហៅ (ស្រាបែបនេះ) ប៉ាវ-លេង-គិរ ។ គឺជាអង្ករ" ។

លោកអាយម៉ូនីញេពន្យល់ថាពាក្យ "លេង-គិរ" នេះត្រូវនឹងពាក្យចារឹកថា រង្គុ (ស្រូវនេះជាអង្ករ) នេះត្រូវដូច្នេះមែន ។ ឯពាក្យថា "ប៉ាវ" នោះខ្ញុំសុំលើកបង្ហាញពាក្យថា ប៉ (ប៉ាយ, បបរ) ក្នុងភាសាសៀង ហើយក្នុងភាសាខ្មែរសព្វថ្ងៃនេះ គ្រាន់តែដាក់ថែមអក្សរប មួយទៀតជាបបរ ។ ស្រាដែលគេធ្វើនឹងអង្ករឆ្អិនឬបាយ នេះជាឈ្មោះស្រាធ្វើពីបាយត្នុះឯង ។

កាំភ្លួលកាំសរ

លោកហាន់–យេន រៀបរៀង

(តមកទំងចប់)

បទទី ១៧

## ការតបស្នងសងគុណ

ឆ្នាំនោះកើតគាំងរាំងស្ងួតហួតហែងដី គ្មានទឹកមួយដំណក់ស្រក់ពីផ្ទៃមេឃមកសោះ កំដៅសុរិយាដុតស្លឹកឈើស្វិតក្រៀមឲ្យឆេះខ្លោចអស់គ្មានសល់ ឯសំណាបដែលកំពុងលាស់ខៀវស្រងាត់រលករលង់ពេញវាលស្រែ កំពុងមានស្នេហ៍មុខបរិបូណ៌ ទាំឲ្យពួកកសិករក្រឡេកមកញញឹមព្រាយ ក៏ផ្លាស់សម្បុរទៅជាក្រហមឆេះអស់ ក្អែកត្របត្អូកក៏ពួកស្រពាំងមើលអ្នកពុំយល់ អ្នកទាំងអស់ស្រងូតស្រងាត់លែងនិយាយស្តី ដេកយកដៃគងថ្ពាល់ជាទុក្ខសញ្ញឹងសញ្ញប់ដកដង្ហើមធំ ចំណែកមេផ្ទះសំឡឹងមើលដោយសេចក្តីករុណា បុត្រាគ្នាដែលកំពុងប្រឡែងលេងជាមួយនឹងបងប្អូនវា ដោយសេចក្តីបរិសុទ្ធចិត្តពន្ធឹកមិនមានភ័យគិតដល់អនាគតសោះ ក៏បង្ហូរទឹកភ្នែកតែក្បាលយ៉ាងក្រៀមក្រោះអស់សង្ឃឹម បារម្ភក្រែងគេអ្នកចិញ្ចឹមមិនបាន ដល់ពេលបាយទារគេបានអ្វីឲ្យ ។

នៅមាត់ស្ទឹងស្រុកកំពង់ធំ មានមនុស្សកណ្តាលអាយុម្នាក់ មុខមិនស្រស់អង្គុយជិតកុមារម្នាក់ គាត់សំឡឹងមើលទឹកហូរលោតទៅឆ្ងាយ

នាំឲ្យគាត់ប្រវត្តិដល់អ្នកដែលឃ្លាតឆ្ងាយពីគាត់ទៅ បានជាគាត់មក
អង្គុយនៅទីនោះពេលល្ងាច រង់ចាំគេត្រឡប់មកវិញ យូរៗ គាត់ដកដង្ហើម
ធំម្តងៗ ដែលសំដែងឲ្យដឹងថាគាត់កើតទុក្ខច្រើនណាស់ ទើបខ្សឹបៗ ថា
"ឱកូនសំឡាញ់ឪពុកអើយ ម្តេចកូនមិនវិលមករកឪពុកវិញ ទុកឲ្យឪពុក
នៅម្នាក់ឯង ប៉ាលន់តួថាខុសមែនហើយ ធ្វើម្តេចមាតុគ្រាមវានាំឲ្យឪពុក
វង្វេងបាត់ស្មារតី លែងដឹងអ្វីទាំងអស់ នាំឲ្យកូនគោងលំបាកវេទនាជា
ច្រើនលើកច្រើនជាន់ តែទេវតាលោកសងសឹកជួសកូនហើយ ឪពុក
សព្វថ្ងៃរស់នៅតែសម្បកខ្លួនទទេប៉ុណ្ណោះ ៖ បើជាដឹងថាមេសុវណ្ណបុប្ផា
វាខាតលក្ខណ៍មែនៗនោះ ឪមិនដល់ម្ល៉េះទេ ទឹកភ្នែកក៏ធ្លាក់តក់ៗ លើ
មុខគាត់ កុមារីយកក្រមាជូតឲ្យ រួចគាត់និយាយតទៅទៀត មើលទៅ
ប៉ាមិនរស់នៅយូរប៉ុន្មានទេ កូនអើយកូនមកវិញ ពីព្រោះឪកាន់តែចាស់
ហើយ ស្រូវក៏ពុំបានជំនួញគ្រប់មុខក៏បង់ខាត មេសុវណ្ណក៏ចាស់ពេល
នេះបានចំជាមេពោះចិត្តទៅ តែថារងកម្មដែរ វាទៅលួចប្តីគេទៀត
ហើយត្រូវប្រពន្ធដើមគេធ្វើបាបជាច្រើន . . . ។

ពេលនោះ មានបុរសម្នាក់ទៀតមានអាយុប្រហែលតាចូលមក
ស្រែកហៅកុមារីថា " សាល្វី! ម្តេចមិនទៅសិតតែយកមកជូនលោក
ឪពិសា"

នាងសាលីក៏ដើរឡើងដើរទៅផ្ទះលើកតែយកមក សោភិតញញឹមទទួលយក រួចគាត់ស្ទាបក្បាលនាងដោយសេចក្ដីពេញចិត្ត "កូនឪពុកពេញចិត្តនឹងកូនណាស់ តើកូនមិនគំនុំគុំគួននឹងឪពុកទេឬអ្វី ដែលឪពុកធ្វើបាបបង់ចិញ្ចឹមកូនឯង?

"ចា៎ះ ទេ" ។

"បើដូច្នោះ ឪពុកសូមផ្ដែកកោនទឹងឯងផងបានទេ?

"ចា៎ះ! ខ្ញុំមានចិត្តត្រេកអរណាស់" ។

"ប្រាកដឬ?

"ចា៎ះ ប្រាកដហើយ"

"មិនតែប្រែទេឬអ្វីផលថ្ងៃក្រោយ?

"ត្រង់ណោះសូមលោកឪពុកជឿចុះ ខ្ញុំនឹងប្រតិបត្តិតាមសេចក្ដីប្ដេជ្ញារបស់ខ្ញុំដល់ផុតជីវិត ចាស់តែគ្មានអ្វីជាក់ស្ដុតាងឲ្យលោកឪពុកជឿជាក់" ។

សោភិតបែរមុខញញឹមមើលមុខឪពុកនាងសាលី ហើយក៏ញញឹមរកគ្នាទៅវិញទៅមក ចុងបន្ទស់គាត់បញ្ចប់គំនិតរបស់គាត់ដោយពាក្យដូច្នេះ "កូន! បើប្រាកដជាព្រមឲ្យឪពុកផ្ដែកកោនមែន ឪពុកអរណាស់ ព្រោះកូនឯស្រឡាញ់ទាំងឪពុកនេះ ឪពុកគ្មានអ្វីសងគុណទេ មានតែសុកិន្ទ្រមួយឪពុកប្រគល់ឲ្យឯង តើឯងព្រមយកសគុណនេះទេ?

សាលីដឹងសេចក្ដីប្រាស់ទឹកអៀនណាស់ ស្ទះទៅចំឪពុកបង្កើតរបស់ខ្លួនតួនមុខបាត់ ឪពុកនាងសាលីមានគំនិតឡើងថា "យើងត្រាំនៅស្រុកនេះតទៅទៀតពុំបានទេ បើដូច្នោះ គាងយើងនាំគ្នាទៅនៅឯព្រែកញ៉ៅឯណោះ ដីងបានប្រកបការរកស៊ីឲ្យបានស្រួលបួលទឹងគេគេះណាកបងយល់ដូចម្ដេច? ដល់ស្រួលបួលសឹមយើងរៀបចំទុកដាក់កូនឲ្យរាំមានផ្ទះសម្បែងឡើង" ។

សោភិតក៏ព្រមព្រៀងតាម ទើបអ្នកទាំង ៣ នោះ នាំគ្នាលក់ផ្ទះសម្បែងដីធ្លី ជញ្ជូនរបស់ទ្រព្យមកនៅឯស្រុកព្រែកញ៉ៅ ប្រកបការរកស៊ីមានមុខមានមាត់ឡើង ។

ថ្ងៃមួយ សោភិតមកលេងផ្ទះប្អូនស្រីឯកុំពេញ ក៏បានជួបទឹងសុកិទ្រជាកូន សុកិទ្របានដឹងថាឪពុកចុះក្រក៏បានរំលែកសម្បត្តិរបស់ខ្លួន ដែលបានទទួលពីម្ដាយមកជូនឪពុកពាក់កណ្ដាល ។

ពេលក្រោយមក សោភិតមកលេងទៀតបានសាកសួរសុកិទ្រថា "កូន! កូនឯងឈប់រៀនចេញពីសាលាហើយ លុមកូនគិតរកប្រពន្ធកូនទៅ តើកូនមានពេញចិត្តកន្លែងណាឬទេ?

"បាទ! ខ្ញុំមានពេញចិត្តដែរ តែមិនទាន់ដាច់ស្រេចនឹងចូលដណ្ដឹងនៅឡើយ ព្រោះចាំលោកប៉ាមើលសិន បើពេញចិត្តបានខ្ញុំបាទប្រថុយ" ។

"កូនឯងស្រឡាញ់ឪពុកទេ?

"លោកប៉ា! កូនស្រឡាញ់លោកប៉ាដូចកាលខ្ញុំនៅពីតូច ពិតមែនជាប៉ាបានប្រព្រឹត្តមិនគប្បីដល់អ្នកមីងកូនក៏មែនហើយ ប៉ុន្តែកូននៅតែចេញពីសាច់ប៉ាដដែល កូននៅជាចំណែកមួយរបស់ប៉ា ហេតុនេះបើប៉ាពេញចិត្តឲ្យកូនធ្វើយ៉ាងណា កូនក៏ព្រមតាមទាំងអស់" ។

"កូន! ឪពុកខុសមែនហើយ តែប៉ាចង់បានឲ្យកូនឯងបានសុខដរាបទៅមុខ ហើយប្រាថ្នាមួយមុខដល់រូបកូន តើកូនព្រមតាមទេ?

"តាមប៉ា ប៉ាមានប្រសាសន៍មកចុះ" ។

"ឱកូន! តាំងពីប៉ាធ្លាក់ខ្លួនមក មានគេជួយថែទាំប៉ាដោយយកចិត្តទុកដាក់ ហើយប៉ាមិនដឹងបានអ្វីសងគុណគេទេ មានតែកូនជួយសងគុណជំនួសប៉ាផងចុះ ឲ្យប៉ាបានសប្បាយដោយសារឯងផង ព្រោះប៉ាកាន់តែចាស់ហើយ" ។

"មានអ្វីប៉ា! ប៉ាប្រាប់ឈ្មោះអ្នកនោះដល់កូនចុះ!!!

"ប្រាកដជាឯងព្រមសងគុណជួសប៉ាឬ?

"បាទលោកឪពុក ប្រាប់ឈ្មោះគេដល់ខ្ញុំឆាប់ៗ ខ្ញុំនឹងទៅសងគុណឥឡូវនេះ" ។

"នាងសាលីណា កូន ប៉ាពេញចិត្តនឹងគំនិតមារយាទនាងណាស់ ប៉ានឹងដណ្ដឹងឲ្យឯង តើឯងយល់ដូចម្ដេច?

ក្អែកសុគ្រីវកំពុងព្រាយពន្លឺដោយសេចក្ដីចង់ដឹង - កំលុកចុះមួយរំពេច សំឡឹងមើលទៅមុខដូចជាប្រាសចាកវិញ្ញាណ បេះដូងរបស់គេក៏បុកអួលមួយរំពេច សំដីសោភិតជាន់ក្រោយនេះ ហាក់ដូចជាអាវុធអ្វីមួយដ៏មុត ចាក់ដោតដើមទ្រូងសុគ្រីវទៅហើយ ឱសេចក្ដីតបស្នងសងគុណអើយ! មកធ្វើឲ្យសុគ្រីវក្ដួលគំនិតប្រែឡាំងក្រាំងដូច្នេះ តើទីងគិតម្ដេចហ្ន៎? បើគូសំឡាញ់របស់កុមារល្អម្ល៉េះ ហើយកុមារស្រឡាញ់នាងខ្លាំងផង ៗ

នៅពេលមួយប៉ព្រិចភ្នែកនោះ រង់ក៏ត្រដាយព្រឹកបានរះពណ្ណរាយ នៅមុខសុគ្រីវ ផ្កាយព្រឹកនេះឯងហើយ ដែលសុគ្រីវបានតាំងចិត្តទឹងយកជាគូគ្រង ការបើរៀនសូត្របានសម្រេចដូចសេចក្ដីប្រាថ្នា ហើយនាងក៏មិនបានបញ្ចេញសញ្ញាអ្វី ដែលនាំឲ្យសេចក្ដីគិតរបស់សុ-គ្រីវអសារឥតការដែរ ចុះឥឡូវបើមកឃ្លាតឆ្ងាយពីនាងដូច្នេះ តែធ្វើម្ដេចបានជាជ្រុលប្ដេជ្ញាឲ្យឪពុកថានឹងប្រតិបត្តិតាម គោនតែកាត់ចិត្តពីស្រឡាញ់ចេញ ៗ មួយវិញទៀត សាលីក៏មានគុណលើសុគ្រីវដែរ ហើយធម្មតាកូនគោនតែតបស្នងសងគុណឪពុកទើបត្រូវតាមគន្លងធម៌ ៗ

សោភិតឃើញកូនស្ងៀម ទើបសួរបញ្ឆាក់តទៅទៀត "ម៉េចកូន! ឯងមិនពេញចិត្តឬ?

"ប៉ាឲ្យកូនស្រឡាញ់ដូចម្ដេចបាន បើសាលីដូចជាប្អូនខ្ញុំបង្កើត"

"បើដូច្នោះ ឯងមិនសងគុណជួសឪពុកទេឬ?

"ខ្ញុំមិនថាដូច្នោះទេ តែពេលនេះខ្ញុំជាប់រៀន" ។

"មិនអីទេ ឲ្យតែឯងព្រម នាងនឹងរង់ចាំឯងបាន" ។

សុភិន្ទ្រក៏នៅស្ងៀម ចាស់ៗ ក៏ព្រមព្រៀងគ្នានឹងរៀបអាពាហ៍-ពិពាហ៍ រវាងសុភិន្ទ្រនឹងនាងសាលីដល់ដាច់ឆ្នាំ ទើបរៀបចំប្រដាប់ប្រដាគ្រប់សព្វ ចំណែកញាតិខាងនាងសាលី ក៏ចង់ឃើញមុខខាងប្រុសឲ្យច្បាស់ ទើបមានសំបុត្រពីសោភិតមកឲ្យសុភិន្ទ្រទៅជួបៗ ដល់ថ្ងៃអាទិត្យ សុភិន្ទ្រក៏ទិញមៀនពីជាលទៅផង លុះដល់ព្រែកព្នៅហើយ ក្រមុំស្រុកនោះក៏ផ្អើលមកមើលគ្រប់គ្នា លាន់មាត់សរសើររូបសុភិន្ទ្រគ្រប់គ្នា "នេះចំជាប្រុសគ្រប់លក្ខណ៍ ល្អហាក់ដូចទេវតាតែម្ដងអើយ តែទាស់ពុកចង្កាច្រើនណាស់ មើលតែកោរហើយគង់ឃើញខ្មៅដែរ បើជាក្លួចកោរជើងមុខជានឹងតក់សាបជាមិនខាន" ។

"អើប៉ុណ្ណឹងហើយ នៅមិនត្រូវចិត្តទៀត គេរកតែពុកចង្កាច្រើនហើយថា តាក់ចុចសាច់ឲ្យតែរសើបបន្តិច តែគ្នាដូចជាមិនពេញចិត្តនឹងប្រមុះស្រួចសោះ" ។

"ប្រមុះស្រួចសមនឹងថ្ពាល់ពេញៗហើយថា ចាំសាញញីទៅយកធ្វើប្ដីទៅ" ហើយក៏នាំគ្នាសើចគិលឡេង ។

ចំណែកសុភ័ក្ត្រឡើងទៅលើផ្ទះធំហើយ លើកដៃសំពះចាស់ទុំ អង្គុយនៅទីសមគួរមួយ ស្រាប់តែឃើញនាងសាលីចេញមក ក៏ភ្ញាក់ខ្លួនព្រើតដោយប្លែកភ្នែកព្រោះបាត់យូរ "បងអញ្ជើញមកយូរហើយឬអ្វី?

សុភ័ក្ត្រវិលតែមើលរូបនាង ក៏ស្រឡាំងកាំងនិយាយអេះអុះមិនបានស័ព្ទ នាំឲ្យចាស់ៗសើចគិលឡើង ហើយញញឹមរកគ្នាជាកិច្ចថាសមគ្នាណាស់ ទើបក្មេងបំរើលើកម្ហូបម្ហាមក សាលីអង្គុយចត់ចែងបំរើបងរបស់នាង "បងអញ្ជើញពីសាឡាច្រើនចុះ មានកំឡាំងជិះឡានវិលទៅភ្នំពេញវិញ កុំឲ្យនារីវិទ្យាល័យគេប្លែកមុខ ដោយចំពោះនាងបុប្ផាផ្កាក្រអូប តែជាម្ហូបដៃអ្នកស្រែមិនបានជាមានឱជារសដូចដៃអ្នកក្រុងទេ តែថាបងគង់មិនកើតម្ហូបដៃអ្នកស្រុកកំពង់ធំឡើយ ទុកជាកើតក៏គង់ចាំបាននៅពេលនេះដែរ" ៗ

"បងមិនកើតទេម្ហូបស្រុកកំពង់ធំ រីឯតែស្នាដៃអ្នកដទៃមិនដឹង បើពិតជាស្នាដៃប្អូននោះបងចាំគ្មានកើត សព្វថ្ងៃនឹកមែនចង់ញុំម្ហូបប្រណិតបែបនេះ មើលចុះដីស្រែក្រៀមស្ងួតហាន់យ៉ាងណាបានក្ញុំកាលណាមុខជាទឹងរែកមុខលើសដើម ទៅវិញមុខជាបុប្ផាផ្កាក្រអូបចេញហើយ ប្រយ័ត្នបុះអូន" ៗ

ចាស់ៗញញឹមបិទមាត់លែងជិតចំអន់ថា "ប្ដីប្រពន្ធគេនេះ ត្រូវដើរគ្នាអើតតែម្ដងហើយ ចំជាគូព្រេងគូសំណាងផងគេ បើម៉ឺងឲ្យក្មេង

កំឡោះឯណោះ ក្មេងមួយកំពង់ធំណាក៏បាន បើតាប់ចិត្តដល់អ្នកធ្វើថែមទៀត" ។

នាងសាលីអៀនខ្លួនតែប៉ុលកុងបាត់ ដល់ពេលសម្រាកខ្លួនសុភិទ្រដេកមិនលក់តាំស្តាប់នាងសាលីនិយាយចេញមិនដាច់មាត់ ដល់ពេលល្ងាចជិះរថយន្តវិលត្រឡប់មកកុំពេញវិញ ក៏ទឹកជល់នាងសាលីជាច្រើនលើកហើយអាណិតខាងឥតប្រៀបបាន ស្រណោះកាលទើបនឹងពីដេកនាងយកសាប៊ូក្រអូបមកឲ្យលុបមុខ យកកន្សែងពោះគោឲ្យជូតស្រណោះសំដីនាងផ្ដាំឲ្យទៅលេងដល់ពេលសម្រាករៀន ស្រណោះផ្ដាំឲ្យយកកំណាត់សារូមកឲ្យនាងផង ស្រណោះគ្រប់ស្រណោះសព្វស្មើរមិនចង់ត្រឡប់មកវិញសោះ ។

លុះសុភិទ្ររៀនច្បាប់បានសម្រេចដូចបំណងហើយ ទើបតាស់ៗហៅបងប្អូនញាតិសន្ដានទាំងភ្ញៀវអ្នកមុខអ្នកការជាច្រើនមកប្រជុំរៀបអាពាហ៍ពិពាហ៍រវាងក្រមការសុភិទ្រ នឹងនាងសាលី យ៉ាងអធិកៈធិកអ្នកទាំងពីររូបនោះក៏បាននៅសេពសុខសប្បាយនឹងគ្នាជាកបមក សោកិតនឹងរត្នានាក៏ស្រស់ស្រលនឹងគ្នាដូចដើមវិញ ។ មិនយូរប៉ុន្មានត្រីសារប៉ិះនេះ បានវិលត្រឡប់ទៅនៅស្រុកកំពង់ធំវិញ ព្រោះក្រមការសុភិទ្រកដកាទៅតាំងឲ្យទៅធ្វើចៅហ្វាយស្រុក ១ កំពង់ធំ នាងសាលីក៏បានឡើងស័ក្ដិជាលោកស្រី ។

ដោយសេចក្ដីព្យាយាមយ៉ាងមាំ លោកសុគន្ធបានបុណ្យស័ក្ដិ សមដូចសេចក្ដីប្រាថ្នា តែលោកមិនបានភ្លេចនៃដល់ក្រស្ដ្រឡើយ តែងមានចិត្តអធ្យាស្រ័យល្អជាដរាប អ្នកស្រុកក៏បានសេចក្ដីសុខគ្រប់គ្នាលែងភ័យដល់ការរំលោភច្បាប់អំពីពុកជការដូចមុនៗ ផុតអំពីចោរទុក្កយ ព្រោះមនុស្សទុច្ចរិតត្រូវធ្វើបាបដោយឥតត្រាប្រណី លោកសុគន្ធព្រមទាំងលោកស្រីមួយអន្ទើដោយញាតិមិត្តរបស់លោក ចេះតែពិសប្បាយរហូតដល់អវសាន មិនយូរប៉ុន្មានឆ្នាំលោកសុគន្ធបានឡើងជាចៅហ្វាយខេត្ត ដោយសេចក្ដីប្រតិបត្តិធម៌និងគុណសម្បត្តិដ៏ឧត្ដម ។

រឿងកំពូលកំសត់ចប់តែប៉ុណ្ណេះ ។

---

## ដំនៀសិល្បសាស្ត្រ

(តមកនឹងចប់)

### ឃុនបណ្ណានុរក្ស ប៊ូ ប៉ូ រៀបរៀង

តែថាបើលោកបង្ខំឲ្យខ្ញុំដេកផ្អៀងតែម្ខាង ៧ ខែ ខ្ញុំមុខជាស្លាប់មិនខានទេ ជីវកកោមារភច្ចឲ្យសេដ្ឋីដេកផ្អៀងម្ខាងទៀត ៧ ខែ សេដ្ឋីដេកបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះក៏ប្រកែកលែងដេក ទើបជីវកកោមារភច្ចឲ្យសេដ្ឋីដេកផ្ងារ ៧ ខែទៀត សេដ្ឋីដេកបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះក៏ប្រកែកលែងដេក ត្រូវពេទ្យប្រាប់ថា បើខ្ញុំមិនកំណត់យ៉ាងនេះទេ មុខជាលោកសម្រាន្តមិនបាន ៧ ថ្ងៃ ៣ ដងដូច្នេះឡើយ ដ្បិតខ្ញុំដឹងជាមុនរួចហើយថា កាលបើលោកសម្រាន្តបាន ៧ ថ្ងៃ ៣ ដងដូច្នេះហើយ ជម្ងឺក្នុងក្បាលលោកមុខជានឹងសះស្បើយពិតប្រាកដ ឥឡូវលោកជាកេតដាច់ស្រឡះហើយ ចូរលោកក្រោកឡើងចុះ សេដ្ឋីក្រោកឡើងហើយក៏ប្រគល់សម្បត្តិទ្រព្យទាំងអស់នឹងខ្លួនឲ្យជីវកកោមារភច្ច ៗ មិនព្រមទទួលយក គ្រាន់តែបង្គាប់សេដ្ឋីឲ្យថ្វាយប្រាក់ ១ សែនរៀលទៅព្រះបាទពិម្ពិសារ ឯឲ្យខ្លួន ១ សែនរៀលទៀតផង សេដ្ឋីក៏ទទួលព្រមតាមបង្គាប់ ។

សម័យនោះ មានកូនប្រុសសេដ្ឋីម្នាក់នៅក្រុងពារាណសី ជាអ្នកលេងល្បែងដាំដូង កើតកេតដុំក្នុងពោះវៀនធំ បរិភោគបាយបបរបួលទៅមិនរលួយ បន្ទោរបង់ក៏មិនស្រួលសោះ ទៅជាស្គមប្រែផក់សម្បុរអាក្រក់លឿងស្លេកស្លាំងឡើងសរសៃពេញទាំងខ្លួន សេដ្ឋី

អាពុកដឹងជាកូនឈឺធ្ងន់ដូច្នោះក៏ទៅឯក្រុងរាជគ្រឹះ ចូលទៅក្រាបបង្គំទូលសូមព្រះរាជានុញ្ញាតព្រះបាទពិម្ពិសារ ឲ្យជីវកកោមារភច្ចទៅមើលជម្ងឺកូន កាលជីវកកោមារភច្ចបានទទួលព្រះរាជានុញ្ញាតហើយក៏ចូលទៅសង្កេតមើលអាការរោគកូនសេដ្ឋីនោះ លុះពិនិត្យដឹងច្បាស់ហើយក៏បណ្ដេញមនុស្សឲ្យចេញមកខាងក្រៅអស់ បាំងរាំងននជិតហើយក៏ចងសេដ្ឋីបុត្រភ្ជាប់នឹងសសរ ឲ្យប្រពន្ធរបស់សេដ្ឋីបុត្រនោះឈរចាំមើលពីខាងមុខប្ដី ចងរួចវះពោះស្រាវយកពោះវៀនធំចេញមកក្រៅ ហើយកាត់យកដុំនោះមកបង្ហាញឲ្យប្រពន្ធមើលប្រាប់ថា ព្រោះតែដុំនេះហើយបានជាប្ដីនាងឈឺបែបនេះ ថា ហើយក៏បញ្ចូលពោះវៀនធំទៅក្នុងពោះវិញរួចដេរភ្ជិតលាបថ្នាំឲ្យ កូនសេដ្ឋីក៏បានជារោគដាច់ស្រឡះពីក្នុងខ្លួន សេដ្ឋីអាពុកបានជូនរង្វាន់គ្រូពេទ្យ ១៦ ពាន់រៀលគ្រូពេទ្យជីវកកោមារភច្ចទទួលយករង្វាន់នោះ ត្រឡប់វិលមកក្រុងរាជគ្រឹះវិញ ។

គ្រានោះ ព្រះបាទបជ្ជោតក្នុងក្រុងឧជ្ជេនីទ្រង់ព្រះអាពាធរោគលឿង មានពួកគ្រូពេទ្យធំៗ ជាច្រើននាក់បានព្យាបាលព្រះរោគនោះមិនសះជាឡើយ ទើបទ្រង់ចាត់ព្រះរាជបម្រើឲ្យទៅសុំគ្រូពេទ្យជីវក-កោមារភច្ចអំពីព្រះបាទពិម្ពិសារមកព្យាបាលព្រះរោគនោះ ឯជីវកកោ-មារភច្ចកាលបានទទួលព្រះរាជានុញ្ញាតពីព្រះបាទពិម្ពិសារ ហើយក៏ទៅឯក្រុងឧជ្ជេនី លុះដល់ហើយបានចូលទៅគាល់ព្រះបាទបជ្ជោតក្រាបបង្គំ

ទូលសួរថា ខ្ញុំព្រះអង្គនឹងស្ងោទឹកដោះគោថ្វាយទ្រង់សោយ តើព្រះអង្គទ្រង់សោយបានឬទេ? ព្រះមហាក្សត្រទ្រង់ត្រាស់ថា មិនបានទេ នាយជីវក អ្នកឯងផ្សំថ្នាំឯទៀតៗ យើងនឹងលេបតែប៉ុន្មានក៏បានទាំងអស់ កុំតែយកទឹកដោះគោមកធ្វើថ្នាំ ដ្បិតខ្ញុំខ្ពើមណាស់ គ្រូពេទ្យជីវកគិតថា ព្រះរោគនេះបើមិនប្រើទឹកដោះគោជាថ្នាំទេ មុខជាមិនជាសះស្បើយឡើយ បើដូច្នោះមានតែអញស្ងោទឹកដោះឲ្យដូចជាទឹកម្លូទាំងពណ៌ទាំងក្លិននិងរស ហើយលាយជាមួយនឹងថ្នាំផ្សេងៗច្រើនមុខទៀត ដើម្បីកុំឲ្យស្តេចទ្រង់ជ្រាប ប៉ុន្តែកាលបើស្តេចបានសោយថ្នាំនេះទៅហើយ គង់តែនឹងជ្រាប លុះបានជ្រាបហើយមុខជានឹងខ្ញាល់យកទោសសម្លាប់អញមិនខាន ហេតុនេះត្រូវតែអញធ្វើឧបាយកល ទូលសុំឱកាសទុកជាមុនឲ្យហើយ គិតឃើញដូច្នេះក៏ក្រាបថ្វាយបង្គំលាចេញទៅស្ងោថ្នាំតាមគំនិតនោះ លុះស្ងោថ្នាំបានស្រេចហើយក៏ចូលមកក្រាបបង្គំទូលសុំព្រះរាជានុញ្ញាតថា បពិត្រព្រះសម្មតិទេព ធម្មតាខ្ញុំព្រះអង្គជាគ្រូពេទ្យ តែងត្រូវការគាស់យកឫសឈើមកធ្វើថ្នាំដោយប្រញាប់ណាស់ ហេតុនេះ សូមព្រះសម្មតិទេពទ្រង់ត្រាស់បង្គាប់ពួកអ្នករក្សាដំរីនិងពួកអ្នករក្សាទ្វារថា បើពេទ្យជីវកត្រូវការយកដំរីណាជិះក៏បាន ត្រូវការចេញចូលទ្វារណាក៏បាន ចង់ចេញចូលពេលវេលាណាក៏បាន កុំឲ្យឃាត់ឃាំងឡើយ ព្រះបាទបជ្ជោតក៏ទ្រង់ត្រាស់បង្គាប់តាមដែលជីវកគោមារភច្ចទូលសុំ កាលបើគ្រូពេទ្យជីវក

បានព្រះរាជានុញ្ញាតដូច្នោះហើយក៏ថ្វាយបង្គំលា យកកាកៈទាសនោះទៅ ព្រះបាទបជ្ជោតរូបក្រាបថ្វាយបង្គំលាថយចេញមកក្រៅ រួយរំពេច ដើរយ៉ាងលឿនសំដៅទៅឯរោងដំរី យកមេដំរីឈ្មោះភទ្ទវតិកា ឡើងជិះបរចេញពីក្រុងឧជ្ជេនីទៅ ឯមេដំរីនេះដើរក្នុង ១ ថ្ងៃបាន ៥០ យោជន៍ ។

គ្រានោះ ព្រះបាទបជ្ជោតទ្រង់សោយព្រះឱសថ ដុតជ្រាបទៅក្នុងព្រះអង្គហើយក៏ទ្រង់បង្អោរចេញមកវិញ បានជ្រាបច្បាស់ថាជាទឹកដោះ ទើបត្រាស់ប្រើរាជបុរសឲ្យរកហៅខ្លួនជីវកកោមារភត្យចូលគាល់ រាជបុរសក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពេទ្យជីវកគាត់ជិះមេដំរីភទ្ទវតិកាបរចេញពីក្រុងបាត់ទៅហើយ ព្រះរាជាទ្រង់ត្រាស់ប្រើកាកៈបុរសឲ្យទៅតាមថា ម្នាលនាយកាកៈ ចូរឯងទៅតាមហៅពេទ្យជីវកឲ្យត្រឡប់មកវិញកុំខាន ១ ទៀតឯងកុំទទួលយករបស់អ្វីបន្តិចបន្តួចពីពេទ្យនោះឡើយ ដ្បិតពួកពេទ្យច្រើនតែមានឧបាយកល ឯកាកៈបុរសនោះដើរក្នុង ១ ថ្ងៃបាន ៦០ យោជន៍ដោយសារមានកំឡាំងអមនុស្សជួយផង កាលបានទទួលព្រះរាជតម្រាស់ហើយ ក៏តាមទៅទាន់ជីវកកោមារភត្យកំពុងបរិភោគបាយព្រឹកនៅពាក់កណ្ដាលផ្លូវជិតនឹងដល់ក្រុងកោសម្ពី ទើបនិយាយនឹងពេទ្យជីវកកោមារភត្យថា លោកគ្រូពេទ្យ ព្រះមហាក្សត្រឲ្យលោកត្រឡប់ទៅវិញ ពេទ្យជីវកកោមារភត្យឆ្លើយថា នែនាយកាកៈ ចូរអ្នកបង្អង់ចាំខ្ញុំបរិភោគបាយរួចសិន ចូរអ្នកមកបរិភោគ

បាយជាមួយនឹងខ្ញុំ  គាកៈបុរសឆ្លើយថា  លោកកុំព្រួយដ្បិតព្រះមហាក្សត្របានផ្តាំខ្ញុំថា  ឯងកុំទទួលយករបស់អ្វីបន្តិចបន្តួចពីពេទ្យនោះឡើយ ព្រោះពួកពេទ្យតែងមានកលមាយាច្រើន  ឯជីវកៈកោមារភច្ចយកថ្នាំដាក់នឹងក្រចកហើយស៊ីផ្លែកន្ទួតព្រៃផឹកទឹក  ហុចផ្លែកន្ទួតព្រៃមួយចំហៀងឲ្យគាកៈបុរសបរិភោគផងប្រាប់ថា  បើដូច្នោះអ្នកគ្រាន់តែបរិភោគផ្លែកន្ទួតព្រៃផឹកទឹកចុះ  នាយគាកៈគិតថា  ពេទ្យនេះហ៊ានស៊ីផ្លែកន្ទួតព្រៃផឹកទឹកខ្លួនឯង  ប្រហែលជាមិនហ៊ានធ្វើអំពើអាក្រក់អ្វីទេ  ទើបគាកៈបុរសទទួលយកផ្លែកន្ទួតព្រៃមួយចំហៀងនោះមកស៊ីរួចផឹកទឹកផង  គ្រាន់តែបរិភោគរួចមួយរំពេចក៏ចុះកកៈដាក់ក្នុងនោះភ្លាម  ទើបសួរពេទ្យជីវកកោមារភច្ចថា  លោកគ្រូពេទ្យ  ខ្ញុំនៅមានជីវិតតទៅទៀតឬទេ  ជីវកកោមារភច្ចប្រាប់ថា  នែនាយគាកៈអ្នកកុំគិតភ័យឡើយ  ខ្លួនអ្នកក្តី ស្តេចកំណាចក្តី  មុខជានឹងបានសះស្បើយរោគតាំងពីថ្ងៃនេះទៅហើយ ប៉ុន្តែស្តេចមុខជាសម្លាប់ខ្ញុំមិនខាន  ហេតុនេះខ្ញុំមិនត្រឡប់ទៅវិញទេ ថា ហើយក៏ប្រគល់មេដំរីឲ្យគាកៈបុរសយកទៅថ្វាយស្តេចវិញ  ទើបចេញពីទីនោះទៅឯក្រុងរាជគ្រឹះនាំរឿងនោះចូលទៅក្រាបបង្គំទូលព្រះបាទពិម្ពិសារ ។

ចំណែកព្រះបាទបជ្ជោតកាលបើបានសះជាព្រះពេនស្រឡះពីព្រះឫក្ដិះហើយ  ក៏ពេកឃើញឧបការៈរបស់គ្រូពេទ្យជីវកកោមារភច្ច  ទើប

ប្រើព្រះរាជបម្រើឲ្យទៅហៅជីវកកោមារភត្យថា សូមឲ្យពេទ្យជីវកមកកុំខានយើងនឹងឲ្យតារ ឯជីវកកោមារភត្យតបវិញថា សូមទ្រង់ព្រះមេត្តាប្រោសកុំព្រួយព្រះរាជហឫទ័យ សូមព្រះសម្មតិទេពគ្រាន់តែទ្រង់រឭកឧបការៈរបស់ខ្ញុំព្រះអង្គបានហើយ ព្រះបាទបជ្ជោតទ្រង់ជ្រាបថាពេទ្យជីវកប្រកែកពុំព្រមចូលមកគាល់ដូច្នោះ ក៏ទ្រង់ផ្ញើសំពត់សិវេយ្យកៈ(១) ១ គូទៅព្រះរាជទានជីវកកោមារភត្យ ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់កើតព្រះរោគទល់ បានអនុញ្ញាតឲ្យគ្រូពេទ្យជីវកកោមារភត្យចូលទៅព្យាបាលព្រះរោគនោះ គ្រូពេទ្យជីវកកោមារភត្យបានអប់ផ្កាឧប្បល ៣ ក្តាប់លាយទឹកថ្នាំផ្សេងៗថ្វាយព្រះដ៏មានព្រះភាគទ្រង់ហិតៗផ្កាឧប្បល ១ ក្តាប់ៗចុះបាន ១០ ដងៗ រួមជាចុះ ៣០ ដង ទើបព្រះដ៏មានព្រះភាគបានស្រួលព្រះអង្គជាប្រក្រតីវិញ ឯជីវកកោមារភត្យបានថ្វាយសំពត់សិវេយ្យកៈ ១ គូនោះដល់ព្រះដ៏មានព្រះភាគៗទទួលហើយទ្រង់អនុញ្ញាតឲ្យភិក្ខុសង្ឃប្រើគហបតីចីវរតាំងពីពេលនោះដរាបមក ។

---

១— បានឮមកថាពួកមនុស្សក្នុងឧត្តរកុរុទ្វីបតែងរុំសាកសពដោយសំពត់នោះឯង ហើយយកទៅចោល មានសត្វបក្សីមានប្រមោយដូចដំរីភាន់សំគាល់នូវសំពត់នោះថាជាដុំសាច់ហើយចាបនាំយកទៅដាក់លើកំពូលភ្នំ ហើយចាប់បកសំពត់នោះចោលចេញហើយស៊ីសាច់សពនោះ ។ វេលានោះពួកអ្នកដើរព្រៃបានឃើញសំពត់នោះ ហើយក៏នាំយកមកថ្វាយស្តេច ។ សំពត់នេះហើយដែលព្រះបាទបជ្ជោតបានមកដោយហេតុយ៉ាងនេះឯង ។ សំពត់សិវេយ្យកៈនេះមួយៗមានដំឡៃរាប់ជាច្រើនសែនរៀល ។

ត្រូវពេទ្យជីវកកោមារភច្ចបានឡើងស័ក្តិយសជាមន្ត្រីជាន់ខ្ពស់ព្រម ទាំងមានសម្បត្តិទ្រព្យច្រើនដូចបានថ្លែងមកហើយនោះ ដោយសារតែការរៀនវិជ្ជាពេទ្យហ្មត់ចត់មុតមាំក្នុងខ្លួន ។

ឯគុណវិសេសរបស់ចំណេះវិជ្ជានេះ ក៏ថាឡើយអ្នករៀនដឹងច្រើនដល់ម៉្លោះ សូម្បីរៀនវិជ្ជាតែមួយមុខប៉ុណ្ណោះតែឲ្យច្បាស់ប្រាកដក៏អាចឲ្យសម្រេចផលប្រយោជន៍ដល់ខ្លួនជាច្រើនបាន ដូចមាន:

## រឿងបុរសរៀនមន្ត

កាលពីព្រេងនាយ មានកុមារម្នាក់លាមាតាបិតាចេញពីស្រុកទៅនៅរៀនសិល្បសាស្ត្រនឹងសំណាក់អាចារ្យម្នាក់នៅស្រុកឆ្ងាយអស់ចំនួនពីរបីឆ្នាំ ក៏ពុំបានរៀនចាំវិជ្ជាណាមួយឡើយ ខំប្រឹងខន្ទេញចាំណាស់តែរប៉ុន្តែភ្លេចអស់ទៅវិញ ឯគ្រូទឹកអាណិតអាសូរសិស្សនោះពេកណាស់ ថ្ងៃមួយបាននាំសិស្សនោះ ចូលទៅក្នុងព្រៃជ្រៅនៅស្ងាត់តែពីរនាក់ ហើយប្រាប់ឲ្យខន្ទេញមន្តមួយបទថា "ឃដេសិ ឃដេសិ កឹការណា ឃដេសិ អហម្បិ តំ ជានាមិ" ប៉ុណ្ណោះ សិស្សនោះខំប្រឹងខន្ទេញមន្តទាល់តែចាំស្ទាត់រត់មាត់លែងភ្លេច ទើបអាចារ្យនិយាយផ្តាំសិស្សថា "មន្ត ១ បទនេះមានគុណវិសេសអស្ចារ្យណាស់ អាចការពារអន្តរាយផ្សេងៗបាន ហេតុនេះ គ្រូឯងត្រូវតាំងព្យាយាមសូត្រទាំងពុកពេលថ្ងៃ

កុំបីបណ្ដែតបណ្ដោយឲ្យភ្លេចឡើយ បើដល់ពេលចូលដំណេក ឯងត្រូវសូត្ររួចសឹមដេក ឯងបានមន្តនេះយកទៅចិញ្ចឹមខ្លួនរស់ ១ ជីវិតហើយ" ផ្ដាំស្រេចហើយក៏ឲ្យស្បៀងអាហារ ដាក់ទៅអាស្រ័យតាមផ្លូវបើកឲ្យសិស្សនោះវិលត្រឡប់ទៅនៅស្រុកខ្លួនវិញ ឯសិស្សនោះសំពះលាអាចារ្យចេញទៅដល់ស្រុកកំណើតខ្លួនវិញ ហើយខំតាំងព្យាយាមសូត្ររំឭកមន្តមិនឲ្យភ្លេចតាមបណ្ដាំគ្រូ ។

មានមួយថ្ងៃ ព្រះមហាក្សត្រក្នុងនគរនោះ ចង់ជ្រាបទឹកចិត្តរបស់បណ្ដារាស្ត្រថា ស្រឡាញ់ឬស្អប់ព្រះអង្គ ក៏ទ្រង់តៀសក្លែងធ្វើជារាស្ត្របន្ទំមិនឲ្យគេស្គាល់ថាជាស្ដេចឡើយ ដល់ពេលអធ្រាត្រស្ងាត់ទ្រង់ចេញទៅតែមួយព្រះអង្គឯង ស្ដេចតាមច្រកល្ហកផ្ទះរៀងៗ ទៅដរាបដល់ផ្ទះបុរសអ្នកចេះមន្ត ស្រាប់តែបានទតឃើញពួកចោរជាច្រើននាក់កំពុងលបកាត់តាសផ្ទាំងផ្ទះអ្នកចេះមន្តនោះ ទើបទ្រង់អែបព្រះអង្គសម្ងំចាំមើលកិរិយាចោរ លុះយូរបន្តិចពួកចោរខ្សឹបប្រាប់គ្នាថា "គងយើង គេដេកហើយឬ" វេលានោះទ្រង់ទតឃើញពួកចោររត់ខ្ចាត់ខ្ចាយទៅ ទ្រង់ទឹកធ្លល់តែក្នុងព្រះទ័យ ហើយស្ដេចវិលចូលព្រះរាជវាំងវិញ លុះព្រឹកឡើងស្ដេចត្រាស់ប្រើពលបុរសឲ្យទៅហៅអ្នកចេះមន្តនោះមក ទើបទ្រង់ត្រាស់សួរថា នែបុរស អ្នកឯងបានរៀនសូត្រ

ចេះជើងអ្វីខ្លះដែរឬ បុរសនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំមានចេះមន្ត ១ បទដែរ អើ បើដូច្នោះ អ្នកឯងបង្រៀនយើងផងបានឬទេ សូមទ្រង់ព្រះមេត្តាប្រោស បង្រៀនបាន ទើបព្រះមហាក្សត្រទ្រង់រៀនមន្តអំពីបុរសនោះទាល់តែចាំស្ទាត់ ទ្រង់ព្រះរាជទានរង្វាន់ដល់បុរសនោះជាច្រើន បុរសក្រាបបង្គំទូលឲ្យទ្រង់សូត្រព្រះមន្តរាល់ថ្ងៃដើម្បីការពារស្រុក ។

ថ្ងៃក្រោយមក មានមន្ត្រីធំម្នាក់ជាសេនាបតីរបស់ព្រះមហាក្សត្រនោះ កើតចិត្តក្រក់ក្បត់ព្រះអង្គចង់សោយរាជសម្បត្តិ ទើបយកប្រាក់ ១ ពាន់រៀលសូកនាយខ្មាន់ព្រះកេសហើយបញ្ចុះឲ្យអារព្រះសុរងស្ដេចក្នុងពេលដែលចូលទៅដាក់ព្រះកេសាថ្វាយ បើបានសម្រេចដូចប្រាថ្នាកាលណា នឹងលើកនាយខ្មាន់ព្រះកេសឲ្យធ្វើជាសេនាបតី ឯនាយខ្មាន់ព្រះកេសក៏ទទួលធ្វើតាមបង្គាប់មន្ត្រីនោះ លុះដល់ពេលដាក់ព្រះមស្សុថ្វាយស្ដេចក៏ត្រូវកាំបិតឲ្យមុត រួចលើកផ្គងឡើងប្រុងនឹងអារព្រះសុរងស្ដេចតែម្ដងឲ្យដាច់ ក៏ស្រាប់តែនឹកមុខញ័រចំប្រប់ទប់ខ្លួនមិននឹងក្រាបទៀបព្រះបាទ ព្រះរាជាទ្រង់ត្រាស់សួរហេតុនោះជ្រាបសព្វគ្រប់ហើយ ទើបបំបរបង់សេនាបតីចេញផុតពីដែន ហើយទ្រង់តាំងបុរសចេះមន្តឲ្យធ្វើជាសេនាបតីវិញ ។

បុរសកំសត់ទុគ៌តដែលបានចំរើនឡើងយសស័ក្តិជាមន្ត្រីថ្នាក់ផុតលេខយ៉ាងនេះ ដោយសារខ្លួនបានទន្ទេញចាំមន្តតែ ១ បទប៉ុណ្ណោះ ហេតុដូច្នោះ បានជាលោកចងសុភាសិតទុកក្នុងច្បាប់ក្រមថា "ប្រាជ្ញបុណ្យផង កើតដោយប្រតិបត្តិ" ។

ចប់

# ធម្មបទភាសិត

លោកគ្រូចៅអធិការ ឯក-ញឹម រៀបរៀង

(តមកនឹងចប់)

## បណ្ឌិតគាថា

### បទ - បដ្ឋកវត្ត

១ - វេរញ្ញាណសម្ពុទ្ធំ   ធម្មច្ឆេទ សុទេសិតំ
សង្ឃញ្ច ស្សោរសម្បុត្តំ   វន្ទាមិ ហោតុ សោត្ថិ មេ ។
ខ្ញុំសូមបង្គំនូវព្រះសម្ពុទ្ធ   មានញាណបរិសុទ្ធក្នុងអង្គការយេ
អោះមុះដូចពេជ្រឥតមន្ទិលទេ   គួរឲ្យយើងគេកើតចិត្តជ្រះថ្លា ។
ព្រមទាំងព្រះធម៌ដែលព្រះសាស្ដា   ទ្រង់ត្រាស់ទេសនាទុកដោយប្រពៃ
ព្រមទាំងព្រះសង្ឃប្រសើរពេកក្រៃ   ជាឱរសថ្លៃនៃព្រះសម្ពុទ្ធ ។
ដែលលោកជាសង្ឃទ្រង់សីលបរិសុទ្ធ   សូស្ដីល្អផុតសូមមានដល់ខ្ញុំ ។

២ - អបជ្ឈាយមលា មន្តា   អនុដ្ឋានមលា ឃរា
មលំវណ្ណស្ស កោសជ្ជំ   បមាទោ រក្ខតោ មលំ ។
មន្តគីរ្តិជាចំណេះទាំងឡាយ   បើមិនសូធ្យាយលោយភ្លេចភ្លាំង
ទីផ្ទះសំបែងមិនខ្នះខ្នែងបាំង   ប្រែកធ្វើផញ្ញាំងនឹងខូចទ្រាំបាន ។

៣ - អលសស្សស្ស កុតោ សិប្បំ   អសិប្បស្ស កុតោ ធនំ
អធនស្ស កុតោ មិត្តំ   អមិត្តស្ស កុតោ សុខំ ។
ធម្មតាសិល្បសាស្ត្រសម្រាំង   មានមកពីណាដល់អ្នកខ្ជិលច្រាំង
ទ្រព្យធនអ្នកគ្មានសិល្បសាស្ត្រសម្រាំង   នឹងមានមុខតាំងចូលមកម្ដេចបាន ។
ទាំងជនជាមិត្តអ្នកឥតធនធាន   កាលណានឹងមានគេរាប់មុខឡើយ -
គោះទាំងបុណ្យស័ក្តិអ្នកគ្មានមិត្តហើយ   ធ្វើដូចម្ដេចឡើយនឹងមានពីណា "

៤- ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ

ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។

បុគ្គលនិយាយច្រើនហួសប្រមាណ មិនគួរឈ្មោះថាជាបណ្ឌិតឡើយ
អ្នកមានក្តីក្សេមគ្មានពៀរភ័យហើយ ព្រះមានបុណ្យឲ្យឈ្មោះថាបណ្ឌិត ។

៥ ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ

អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

ប្រយោជន៍លោកនេះនិងលោកខាងណាយ បណ្ឌិតទាំងឡាយមានប្រាជ្ញាខ្ជាប់ខ្ជួន
ព្រោះដឹងប្រយោជន៍របស់ផងខ្លួន ទាំងពីរមាំមួនឈ្មោះថាបណ្ឌិត ។

៦- លោភំ កោធំ មទំ មានំ ឧជ្ឈី ឥស្សំ បមត្តតំ

សោណ្ឌំ ឆិត្វា សុរំ មជ្ជំ មច្ឆេឧញ្ញំ ជហេ ពុធោ ។

សេចក្តីធំពាក់នឹងក្រោធស្រវឹង កាន់ខ្លួនខ្ជិលនឹងច្រណែនធ្វេសល្បែង
ផឹកច្រើនលប់គុណកំណាញ់នេះឯង អ្នកប្រាជ្ញលោកតែងតែលះចោលចេញ ។

៧- សទ្ធា ហិរិច ឱត្តប្បំ ពាហុសច្ចំ វីរិយំ សតិ

បញ្ញា ច សត្តធម្មេតិ សម្បន្នោ បណ្ឌិតោ មតោ ។

ជឿនឹងខ្មាសបាបខ្លាចបាបស្តាប់ច្រើន សង្កាតចំរើនសតិបញ្ញា
ប្រកបដោយធម៌ ៧ ប្រការ នេះលោកហៅថាបណ្ឌិតពិតមែន ។

៨- ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ

ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ

កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ

មនសា សំវុតោ សាធុ សាធុ សព្វត្ថ សំវរោ

សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

សង្គ្រោះក្នុងលោកៈយាចា    សង្គ្រោះដីក្លាកាយវាចាចិត្ត
សង្គ្រោះសព្វថាឱ្យបានតាមក្រិត្យ    ជាគុណល្អពិតផុតទុក្ខទាំងពួង ។

សព្វំ សុណាតិ សោតេន    សព្វំ បស្សតិ ចក្ខុនា
ន ច ទិដ្ឋំ សុតំ ធីរោ    សព្វំឧជ្ឈិតុមរហតិ ។

គេស្ដាប់សំឡេងដោយទ្វារសោតា    គេឃើញរូបាដោយសារតែភ្នែក
ជនមានប្រាជ្ញច្រើនជាអនេក    កុំមានចិត្តបែកចង់បានរូបឡើយ ។

១០ - សុស្សូសា សុតវឌ្ឍនា    សុតំ បញ្ញាយ វឌ្ឍនំ
បញ្ញាយ អត្ថំ ជានាតិ    ញាតោ អត្ថោ សុខាវហោ ។

សេចក្ដីចេះដឹងនឹងការចំរើន    មកពីស្ដាប់ច្រើនទំលះលោភោ
សេចក្ដីចំរើនដោយលះទោសា    លះចិត្តមោហោចេះដុះបញ្ញា ។
បញ្ញាអាស្រ័យញាណល្អជា    ប្រយោជន៍ការងារចេះគិតខ្នះខ្នែង
ប្រយោជន៍ដែលដឹងហើយប្រឹងស្វះស្វែង    ប្រយោជន៍នោះតែងនាំសុខមកឲ្យ ។

១១ - សីលំ យាវ ជរា សាធុ    សទ្ធា សាធុ បតិដ្ឋិតា
បញ្ញា នរានំ រតនំ    បុញ្ញំ ចោរេហិ ទុហរំ ។

សីលល្អប្រពៃទាំងក្មេងទាំងចាស់    សទ្ធាល្អណាស់ប្រជាប់តែងតាំង
បញ្ញាជាកែវនៃជនសម្រាំង    បុណ្យឲ្យក៏បាំងចោរលួចពុំបាន ។

១២ - ចក្ខុមាស្ស យថា អន្ធោ    សោតវា ពធិរោ យថា
បញ្ញវាស្ស យថា មូគោ    ពលវា ទុព្វលោរិវ
អត្ថអត្ថេ សមុប្បន្នេ    សយេយ្យមតសាយិតំ ។

មនុស្សមានភ្នែកជាតែដូចភ្នែកខ្វាក់    ត្រចៀកឮជាក់តែដូចថ្លង់ខ្លាំង
មនុស្សមានបញ្ញាតែដូចគរគាំង    មនុស្សមានកំលាំងតែដូចមនុស្សខ្សោយ
កាលកើតប្រយោជន៍ត្រឡប់ប្រែក្រោយ    ប្រាសចាកបណ្ដោយដូចជាមនុស្សស្លាប់ ។

១៣- ឧស្សាហោ វេរិមិត្តំ  អលសោ មិត្តវេរិ

វិសំវិយាមតំវិជ្ជា  បមាទោ អមតំ វិសំ ។

សេចក្ដីឧស្សាហ៍ហាក់ដូចសត្រូវ  តែត្រឡប់ទៅជាមិត្តយ៉ាងខ្លាំង
ក្ដីខ្ជិលហាក់ដូចជាមិត្តសម្រាំង  តែត្រឡប់តាំងមកជាសត្រូវ
វិជ្ជាហាក់ដូចជាពិសពេកក្រៃ  តែឈ្មោះថាផ្លូវមិនស្លាប់សោះឡើយ
សេចក្ដីប្រមាទមិនស្លាប់ហើយ  ត្រឡប់គ្រឹះអើយក្លាយទៅជាពិស ។

១៤- អម្ពុំ បវត្តំ នោ ឆដ្ឋា  រុក្ខា ខាទន្តិ នោ ផលំ

មេឃោ កាទាចិ នោ សស្សំ  បរត្ថាយ សតំ ធនំ ។

ស្ទឹងដាក់ទឹកទុកមិនផឹកខ្លួនឯង  ទោះឈើដែលតែងតែផ្លែរាល់ប្រាំង
មិនដែលស៊ីផ្លែដែលខ្លួនផ្លែខ្លាំង  បញ្ចេញឆកតាំងទុកឲ្យគេស៊ី
ទឹកភ្លៀងធ្លាក់មកឲ្យដីមានជីរ  ក៏មិនដែលស៊ីសន្ទូងអ្នកស្រុក
ទ្រព្យនរជនរកបានមកទុក  បំណេរទៅមុខប្រយោជន៍តែគេ ។

១៥- រុក្ខោ សុភូមិនិស្សាយ  បុរូឌលំ បវឌ្ឍតិ

សប្បុរិសូបនិស្សាយ  មហាបុញ្ញំ បវឌ្ឍតិ ។

ដើមឈើអាស្រ័យដីដ៏ល្អជា  តែងនឹងមានផ្កាចំរើនឡើង
អ្នកដែលអាស្រ័យសប្បុរសថ្កុំថ្កើង  ចំរើនបុណ្យឡើងទៅជាធំបាន ។

១៦- ហិតំ កាភេ បរោ ពន្ធុ  ពន្ធុបិ អហិតោ បរោ

អហិតោ ទេហជោ ព្យាធិ  ហិតមារញ្ញមោសធំ ។

អ្នកដទៃទេគេឲ្យប្រយោជន៍  ច្រើនតិចដោយហោចជាញាតិស្និទ្ធខ្លាំង
ញាតិសាច់ខ្លួនមែនប៉ុន្តែចិត្តខ្លាំង  ញាតិនោះក៏តាំងជាអ្នកដទៃ ។
ដូចព្យាធិដែលកើតក្នុងកាយសព្វថ្ងៃ  ជាភេទចង្រៃគ្មានប្រយោជន៍សោះ
ឈើវល្លិ៍ជាថ្នាំនៅព្រៃឯនោះ  ខ្ញុំឈើយកគុះលាបផឹកជាបាន ។

១៧-ជិឃច្ឆា បរមា រោគា វិស្សាសា បរមា ញាតិ
សន្តុដ្ឋី បរមំ ធនំ និព្វានំ បរមំ សុខំ ។

សេចក្តីស្រេកឃ្លានជារោគយ៉ាងខ្លាំង ស្និទ្ធស្នាលខ្លួនតាំងជាញាតិប្រសើរ
សន្តោសជាទ្រព្យសមតាមដំណើរ និព្វានប្រសើរសុខយ៉ាងក្រៃលែង ។

១៨-មុទ្ធស្សិសេដ្ឋ បទេសេន កុធារី សរណោន ច
ខលសត្តហិ សំយោគោ បណ្ឌិតោ ប្បរសីទតិ

ទុកជាអ្នកប្រាជ្ញគង់ធ្លាក់ខ្លួនបុះ ព្រោះប្រដៅខុសឲ្យគេកាន់លង់
ទំនៀមទំលាប់ដល់សិស្សដែលល្ងង់ មិនអាចទ្រទ្រង់ពាក្យប្រដៅបាន
ព្រោះមានស្រ្តីអាក្រក់ភប់អាន ជាទីពឹងប្រាណពំនាក់និច្យនៅ
ព្រោះប្រកបដោយបុគ្គលល្ងង់ខ្លៅ មានចិត្តខឹងក្តៅសត្រូវដល់ខ្លួន ។

១៩-អសន្តំ សម្បយោគេន សន្តោបិ អសន្តោ ភវេ
មន្តោ កាចវយុត្តោ ឧជុម្បិ អសាធុ ភវេ ។

ស្លូតប្រសប្បុរសគង់គ្រឡប់រេ ដោយសេពគប់គេអសប្បុរស
ដូចជាផ្លូវថ្មីលំភបស្មើទាំងអស់ សម្រាមពេញសស់ត្រង់មិនល្អ ។

២០-ហិតេសនោ សុមិត្តោ ច វិញ្ញូ ច ទុល្លភោ ជនោ
យថោសធញ្ច សាធុញ្ច ភេសជ្ជារ៍ ច សជ្ជនោ

អ្នកដែលស្វែងរកប្រយោជន៍ឲ្យគេ ហាក់ដូចជាមានចិត្តល្អពេញពោរ
ជាអ្នកមានប្រាជ្ញមិនបានទន់ទោរ ដោយមិនលោភោរ៍ ក្នុងលោក ។
ដូចថ្នាំនឹងសម្រាប់រម្ងាប់រោគ មានទឹកជាដោករសឆ្ងាញ់ពិសា
បំបាត់រោគបានហើយឆ្ងាញ់ទៀតណា ថ្នាំនោះជាការក្រៃដូចគ្នា ។

៦១- លុទ្ធមត្ថេនគណ្ហេយ្យ ថទ្ធមញ្ជលិកម្មុនា

ឆន្ទានុវត្តិយា មុឡ្ហំ យថា ភូតេន បណ្ឌិតំ ។

ផ្គាប់ចិត្តជនលោភដោយឲ្យប្រយោជន៍ ផ្គាប់រឹងត្អឹងដោយបង្គំភ្ញាក់

ផ្គាប់ចិត្តជនល្ងង់ដោយមិនរាំង ផ្គាប់អ្នកប្រាជ្ញតាំងតាមសេចក្តីពិត ។

## មិត្តវគ្គ

៦២- អហិតេ បដិសេធោ ច ហិតេសុ ច និយោជកា

ព្យសនេចាបរិច្ចាគោ សខេយំ មិត្តលក្ខណំ ។

ហាមប្រាមគ្នីគ្នាក្នុងកាលឥតផល នាំគ្នាឲ្យដល់ប្រយោជន៍យ៉ាងខ្ជាប់

មិនលះបង់គ្នាគ្រាក្រភាន់ភាំង លក្ខណៈមិត្តតាំងណាទុកសង្ខេប ។

៦៣- សត្ថោ បវសតោ មិត្តំ មាតា មិត្តំ សកេ ឃរេ

សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ

សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ ។

បក្សពួកជាមិត្តនៃអ្នកដើរផ្លូវ មាតាមិត្តនៅក្នុងផ្ទះខ្លួនខ្ជាប់

អ្នកមានចិត្តស្មើជាមិត្តសម្រាំង គ្រាភ័យភាន់ភាំងមានទុក្ខកើតឡើង ។

បុណ្យខ្លួនធ្វើហើយជាមិត្តថ្កុំថ្កើង ជួយទំនុកយើងនៅក្នុងភពមុខ ។

៦៤- សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគប្បីសេពសប្បុរស គួរស្និទ្ធស្នាលអស់ឥតទោសា

ដឹងធម៌សប្បុរសមិនមានមោហា ចិត្តគ្មានទន់ទោរទៅកាន់បាបឡើយ ។

៦៥- សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ បញ្ញា លព្ភតិ នាញ្ញតោ ។

បុគ្គលគប្បីសេពសប្បុរស គួរស្និទ្ធស្នាលអស់ឥតចិត្តទោរសោ
ព្រោះមិនសប្បុរសមិនបានទន់ទេរ តែងបាត់មោហៈបាននូវប្រាជ្ញា ។

២៦– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោចតិ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់អំពីចិត្តខ្លួន
ព្រោះដឹងច្បាស់ធម៌សប្បុរសមាំមួន តែងរុងរឿងខ្លួនបណ្ដាលពួកញាតិ ។

២៧– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា គច្ឆន្តិ សុគតឹ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់កុំមានចិត្តទឹង
ទាំងធម៌សប្បុរសត្រូវតែទំព្រឹង អ្នកដែលចេះដឹងតែងទៅឋានសួគ៌ ។

២៨– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា តិដ្ឋន្តិ សាតតំ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់កុំលាក់បិទបាំង
ទាំងធម៌សប្បុរសចេះឲ្យសម្រាំង អ្នកនោះបានតាំងសុខទៀងវែងឆ្ងាយ ។

២៩– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់អំពីចិត្តខ្លួន
ព្រោះដឹងច្បាស់ធម៌សប្បុរសមាំមួន រមែងរួចខ្លួនរួចទុក្ខទាំងពួង ។

៣០- ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។

បុគ្គលមិនត្រូវសេពបាបមិត្ត មិនគួរចូលចិត្តជនទាបថោកទេ
ត្រូវសេពនឹងមិត្តកល្យាណ គួរសេពនឹងគេបុរសខ្ពង់ខ្ពស់ ។

៣៥. ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ ។

អ្នកដែលនៅរួមជាមួយនឹងពាល សោយសោកអស់កាលយូរកើតពាលោ
នៅរួមនឹងពាលនាំទុក្ខពេញពោរ ដូចនៅនឹងចោរដែលជាសត្រូវ ។
នៅរួមអ្នកប្រាជ្ញបានសុខពេកក្រៃ បីដូចជានៅរួមនឹងពួកញាតិ ។

៣៦. អញ្ញទត្ថុហរោ មិត្តោ យោ ច មិត្តោ វចីបរោ
អនុប្បិយញ្ច យោ អាហ អបាយេសុ ច យោ សខា ។

មិត្តណាដែលគិតតែពីចង់បាន របស់ធនធានពីមិត្តផងគ្នា
មិត្តណាដែលបានតែមានវាចា ពីរោះពីសាត្រឹមចុងមាត់លេង ។

៣៧- ឯតេ អមិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
អារកា បរិវជ្ជេយ្យ មគ្គំ បដិភយំ យថា ។

អ្នកប្រាជ្ញដឹងច្បាស់មិត្ត ៤ ពួកនោះ មិនពិតដូច្នោះត្រូវឈប់ស្នេហា
ចៀសពីមិត្តនោះឆ្ងាយចៀសពស់ខ្លា ដូចអ្នកត្រូវការដើរចៀសផ្លូវភ័យ ។

៣៨. ឧបការោ ច យោ មិត្តោ សុខទុក្ខោ ច យោ សខា
អត្ថក្ខាយី ច យោ មិត្តោ យោ ច មិត្តានុកម្បកោ ។

មិត្តណាអ្នកមានឧបការៈ សំឡាញ់ណាអ្នករួមសុខទុក្ខ
មិត្តណាអ្នកណែប្រយោជន៍ពេញពោរ មិត្តណាចិត្តទោរទន់អនុគ្រោះ ។

៣៩. ឯតេបិ មិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
សក្កច្ចំ បយិរុបាសេយ្យ មាតា បុត្តំវ ឱរសំ ។

អ្នកប្រាជ្ញដឹងច្បាស់មិត្ត ៤ ពួកនោះ ប្រាកដនូវឈ្មោះថាមិត្តសម្រាំង
អង្គុយជិតមិត្តស្និទ្ធឥតបិទបាំង ដូចមាតាតាំងចិត្តនឹងកូននោះ ។

៣៦. បាបមិត្តេ វិវជ្ជេត្វា ភជេយ្យុត្តមបុគ្គលំ
ឱវាទេ ចស្ស តិដ្ឋេយ្យ បត្ថេន្តោ អចលំ សុខំ ។

បុគ្គលប្រាថ្នាសុខមិនកក្រើក គប្បីតែលើកលែងមិត្តបាបខ្លាំង
ត្រូវសេពបុគ្គលឧត្តមសម្រាំង ហើយមានចិត្តតាំងក្នុងឱវាទគេ ។

(ចប់មិត្តវគ្គ)

៣៧. ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ

អ្នកប្រាជ្ញគួរប្រៀនប្រដៅពួកជន ហាមគេឲ្យទន់ចាកក្ដីពាលោ
ប្រាជ្ញនោះនឹងបានជាទីបិយោ សប្បុរសស្នេហា ស្នេហាទាំងអស់ ។
តែមិនជាទីស្រឡាញ់របស់ អសប្បុរសទាំងឡាយនោះឡើយ ។

៣៨. ទុល្លភោ បុរិសាជញ្ញា ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតិ ធីរោ តំ កុលំ សុខមេធតិ

បុរសអាជានេយ្យកម្ររកបាន មិនកើតសព្វស្ថានគ្រប់ទីកន្លែង
កើតត្រកូលណាជួយជិតតាក់តែង ត្រកូលនោះឯងឲ្យបានសុខា ។

៣៩. យថា បនសា បក្កា ពាហិ កណ្ដកមេវ ច
អន្តោ អមតបូរណា [illegible]

ផ្លែខ្នុរទុំខាងក្រៅបន្លារ ក្នុងមានរសជារសដូចអម្រិត
ជនខ្លះ នៃនរជាអ្នកមានចិត្ត ស្អាតល្អប្រព្រឹត្តក៏ដូច្នោះឯង ។

៤០- អនាគតំ ភយំ ទិស្វា ទូរតោ បរិវជ្ជយេ
អនាគតញ្ច ភយំ ទិស្វា អភីតោ ហោតិ បណ្ឌិតោ
បណ្ឌិតឃើញភ័យមុនមកដល់កាយ ជៀសវាងពីឆ្ងាយឲ្យផុតស្រឡះ
លុះភ័យមកដល់លោកដូចប្រទះ លោកដែលស្គាល់ច្បាស់មិនតក់ស្លុតឡើយ។

៤១- គណ្ឌិដ្ឋានេ ឯកបទេ ជាតិមញ្ញេយ្យ បណ្ឌិតោ
តិមកោវេឡុបព្ភារេ តិមហាទិបកាណុកោ
បទធម៌ណាមួយអ្នកប្រាជ្ញចងហើយ កុំមើលងាយឡើយថាខុសទទេ
ដូចព្រះអាទិត្យបំភ្លឺឃើញគេ ដូចម្តេចនឹងរហាយដាឫស្សី ។

៤២- គុណាទោសេសុនេកោច អត្ថិកោ ច វិវជ្ជិតោ
សុខុមាលបទុមស្ស ឆទ្ទំ ភវតិកាក្ខទ្ទំ
អ្នកណាមួយវៀរចាកគុណនឹងទោស គឺត្រូវនឹងខុសតែមួយពុំបាន
ប៉ុនជាតិផ្កាឈូកដែលគេរាប់អាន ថាល្អគង់មានទងនៅគ្រោតគ្រាត ។

៤៣- អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ
យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ
យោច សព្វទទោ ហោតិ យោ ទទាតិឧបស្សយំ
អមតន្ទទោ ច សោ ហោតិ យោ ធម្មំ អនុសាសតិ
ការឲ្យទានបាយដូចឲ្យកំលាំង ឲ្យគ្រឿងបិទបាំងដល់គេស្លៀកពាក់
ដូចឲ្យសម្បុរពណ៌ដល់នាងអ្នក ព្រោះគ្រឿងស្លៀកពាក់ឲ្យល្អស្មើមុខ ។
ឲ្យយានជិះដូចឲ្យក្តីសុខ ឲ្យប្រទីបទុកដូចឲ្យភ្នែក
អ្នកឲ្យទីនៅដូចឲ្យចំណែក របស់គ្រប់បែបរបស់ទាំងនោះ ។
អ្នកប្រដៅធម៌ដោយអនុគ្រោះ ចិត្តស្មោះចំពោះឲ្យគេបានត្រូវ
ដូចដឹកដៃទាក់ឲ្យដើរត្រង់ផ្លូវ អ្នកនោះលោកហៅថាឲ្យនិព្វាន ។

៤៤- តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រូវមានស្មៅជាទោសឲ្យអាក់ សត្វមានរាគៈជាទោសដល់បាណ
ទានដ៏នឲ្យហើយក្នុងលោកដែលគ្មាន រាគៈនោះបានផលច្រើនពេកក្រៃ ។

៤៥- តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រូវមានស្មៅជាទោសឲ្យអាក់ សត្វមានទោសៈជាទោសដល់ប្រាណ
ទានដ៏នឲ្យហើយក្នុងលោកដែលគ្មាន ទោសៈនោះបានផលច្រើនពេកក្រៃ ។

៤៦- តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រូវមានស្មៅជាទោសឲ្យអាក់ សត្វមានមោហៈជាទោសដល់ប្រាណ
ទានដ៏នឲ្យហើយក្នុងលោកដែលគ្មាន មោហៈនោះបានផលច្រើនពេកក្រៃ ។

៤៧- តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វីតតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រូវមានស្មៅជាទោសណាស់ណា សត្វមានឥច្ឆាជាទោសដល់ប្រាណ
ទានដ៏នឲ្យហើយក្នុងលោកដែលគ្មាន ឥច្ឆានោះបានផលច្រើនពេកក្រៃ ។

យំកិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា តិទសេ សុគតំ គតំ
យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ

យេ តំ កតំ សុចរិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ
សព្វេលោកម្ហិយេសត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា ។

កុសលកម្មតិចតួចឯណា ដែលខ្ញុំជិះថ្លាហើយខ្ញុំបានធ្វើ
ដោយកាយវាចាចិត្តខ្ញុំអើពើ គួរនាំទៅលើកើតស្ថានត្រៃត្រិង្ស ។
សត្វមានសញ្ញាឯណាបានដឹង បុណ្យដែលខ្ញុំប្រឹងខំធ្វើនេះក្តី
សូម្បីពួកសត្វផងអសញ្ញី កំខ្ញុំតប្បីចែកបុណ្យនេះឲ្យ ។
ថាបើពួកសត្វទោះមិនដឹងហើយ កំខ្ញុំសូមឲ្យទេវតាមានឫទ្ធិ
អញ្ជើញទៅប្រាប់ទៅផងស់តៀនចិត្ត ដោយក្តីអាណិតសត្វក្នុងលោក ។
ឲ្យបានដឹងនេះហើយដោយចិត្តមេត្តា ត្រេកអរគ្រប់គ្នាក្នុងលោកទាំងមូល
សូមមានអាហាររស់នៅដោយស្រួល ដោយបានទទួលផលបុណ្យនេះហោង ។

---

# ពិធីប្រគល់ព្រះរាជក្រឹត្យ

## ដល់ព្រះសង្ឃនិងគ្រហស្ថដែលបានទទួលយសស័ក្តិថ្មី

កាលនៅថ្ងៃ២៩ ខែធ្នូ រីមប្រ ឆ្នាំ ១៩៤៤ វេលារសៀលម៉ោង ១៦ (ម៉ោង ៤) លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ (ពៀរ. ឌុយប៉ុងត៍) បានធ្វើសន្និបាតប្រជុំព្រះសង្ឃក្រុមជំនុំប្រែព្រះត្រៃបិដក ព្រះសង្ឃជាអាចារ្យសាលាបាលីជាន់ខ្ពស់ និងក្រុមអ្នកការក្រសួងពុទ្ធសាសនបណ្ឌិត្យទាំងអស់ ព្រមទាំងអ្នកសាមីខ្លួនដែលត្រូវបានទទួលយសស័ក្តិ ឲ្យមកជួបជុំគ្នានៅទីស្នងធំកណ្តាល លុះជួបជុំហើយ លោកអគ្គលេខាធិការមានប្រសាសន៍ថា:

"ដោយហេតុដែលព្រះករុណាគ្រប់អង្គ និងអស់លោក-អ្នកពលគ្នា ខំយកចិត្តទុកដាក់ធ្វើការឲ្យបានចំរើន ដល់ក្រសួងពុទ្ធសាសនបណ្ឌិត្យមកពីឆ្នាំមុនៗ នោះហើយបានជាមកដល់ថ្ងៃនេះ យើងទើបបានឃើញភស្តុតាងដ៏ជាក់ស្តែងចំពោះមុខ គឺព្រះករុណាអម្ចាស់ជីវិតលើត្បូង និងលោកនាយកអាណាព្យាបាលក្រុងកម្ពុជា ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានសមណស័ក្តិនិងយសស័ក្តិ ដល់ព្រះករុណាអង្គខ្លះ និងលោក-អ្នករូបខ្លះដើម្បីជាបំណាច់ដល់កំឡាំងព្យាយាមនេះ ។

វេលានេះ ខ្ញុំសូមរំលឹកជាថ្មីទៅមុខទៀតថា ក្រសួងពុទ្ធសាសនបណ្ឌិត្យនេះ ដែលនឹងបានលូតលាស់ចំរើនច្រើនៗ ឡើងនោះ មិនមែនដោយកំឡាំងមនុស្សតែម្នាក់ៗ ទេ អាស្រ័យដោយការរួបរួម

កំឡាំងទាំងអស់គ្នា តាមការប្រឹងធ្វើឲ្យបានសម្រេចតាមមុខការរៀនខ្លួនមិនបណ្ដែតបណ្ដោយ មិនអាងតែគេ មិនប្រមាថគ្នា យ៉ាងនេះទើបបានចំរើន ប្រសិនបើមានអ្នកខ្លះខំធ្វើ អ្នកខ្លះទម្រន់ខ្ជិលធ្វើ ដូច្នេះមិនជាយូរប៉ុន្មានទេ ក្រសួងពុទ្ធសាសនបណ្ឌិត្យមុខជានឹងរអិលថយក្រោយវិនាសសាបសូន្យទៅវិញមិនខាន គតិនេះទៅ ត្រូវយើងពួតដៃគ្នាខិតខំធ្វើការឲ្យមុឹងមាំ ឲ្យរឹតតែបានកើនជឿនទៅមុខទៀតទៀត ដើម្បីនឹងជួយដឹកនាំប្រទេសជាតិឲ្យស្ទុះទៅដល់ឋានដ៏ខ្ពង់ខ្ពស់ ។

នៅទីបំផុតនេះ ខ្ញុំមានចិត្តត្រេកអរជាពន្លឹក ក្នុងការដែលព្រះករុណា ទ្រង់អស់អ្នកទាំងឡាយ មានព្យាយាមបានបំពេញកិច្ចការរៀនខ្លួនយ៉ាងពេញលេញមកហើយនេះ ។

កាលលោកអគ្គលេខាធិការមានប្រសាសន៍ចប់ហើយ ក៏បានប្រគេនព្រះរាជក្រឹត្យដល់ព្រះសង្ឃ ៣ អង្គ និងឲ្យដល់គ្រហស្ថ ៩ នាក់ដូចតទៅនេះ;

## ខាងព្រះសង្ឃ៣អង្គ

១— លេកត្រ មាស—សុវណ្ណ ជាក្រមជំនុំថែព្រះត្រៃបិដក អាយុ ៤៣ ឆ្នាំ វស្សា ២២ ត្រូវតាំងជាព្រះគ្រូ "ធម្មកោសល" ទីឋានា គណធម្មយុត្តិ វត្តស្វាយពពែ (ក្នុងពេញ) ។

២— លោកគ្រូ ឡុង-បាន ជាសាចារ្យសាលាបាលីជាន់ខ្ពស់ អាយុ ៤១ ឆ្នាំ វស្សា ២០ ត្រូវតាំងជាទីព្រះគ្រូ "បញ្ញាវិទូ" ទីឋានា គណមហានិកាយ វត្តសារាវ័ន (ភ្នំពេញ) ។

៣— លោកគ្រូ យ៉ាញ-អ៊ុន ជាក្រុមជំនុំប្រែព្រះត្រៃបិដក អាយុ ៣១ ឆ្នាំ វស្សា ១១ ត្រូវតាំងជាទីព្រះគ្រូ "ឧត្តរត្ថកត" ទីឋានា គណធម្មយុត្តិ វត្តស្វាយពពែ (ភ្នំពេញ) ។

## ខាងគ្រហស្ថ ៩ នាក់

៤— ព្រះនាយកមន្ត្រី យៀន-ចឹម ជាគូឈ្មួយនៃលោកអគ្គលេខាធិការ ត្រូវឡើងជាទី "ឧកញ៉ានាយកមន្ត្រី" ស័ក្តិ ៧ ហ៊ូពាន់ ។

៥— លោកញុង-សឿង ក្រុមជំនុំប្រែព្រះត្រៃបិដក ត្រូវតាំងជាទី "ឃុនសុន្ទរមេធី" ស័ក្តិ ៤ ហ៊ូពាន់ ។

៦— លោក ឈឹម-ណាក សៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនបរិក្សប្រតិភាណ" ស័ក្តិ ៤ ហ៊ូពាន់ ។

៧— លោក គី-គិមស៊ីវ សៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនសមគ្គប្រជា" ស័ក្តិ ៤ ហ៊ូពាន់ ។

៨—លោក ស-សឿន រៀនសាលាបាលីជាន់ខ្ពស់ ត្រូវតាំងជាទី "ឃុនវិចិត្រវេទី" ស័ក្តិ ៤ ហ៊ូពាន់ ។

៩— លោក អ៊ឹម-កន រៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនសោភ័ណភ័ក្តិ" ស័ក្តិ ៤ ហ៊ូពាន់ ។

១០— លោក ហង់-ឌឿ គ្រូបង្រៀនសំស្រ្កឹតនៅសាលាបាលីជាន់ខ្ពស់ ត្រូវតាំងជាទី "ឃុនសកជានុសិដ្ឋ" ស័ក្តិ ៤ ហ៊ូពាន់ ។

១១— លោក មាស-យុត រៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុន-សុមេធមន្រ្តី" ស័ក្តិ ៤ ហ៊ូពាន់ ។

១២—លោក ជិត-ប៊ុន រៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនវោហារវិចិត្រ" ស័ក្តិ ៤ ហ៊ូពាន់ ។

---

ភ្នាក់ងារនៃពុទ្ធសាសនបណ្ឌិត្យ

បានទទួលព្រះរាជទានគ្រឿងឥស្សរិយយស

កាលពីថ្ងៃ ៨ ណូវែម្ប៊្រឆ្នាំ ១៩៤៤ នៅឱកាសដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះសីហនុ-វរ្ម័នស្តេចយាងទៅទ្រង់ទស្សនាការមន្ទីរអាល្បែរសារ៉ូត៍ នោះទ្រង់ព្រះកជទានគ្រឿងឥស្សរិ-

យយស (មេដៃយ៍) ដល់ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យ ដូចមាននាម-ខាងក្រោមនេះ៖

## អស្សរិទ្ធិនៃក្រុងកម្ពុជា

ឃុនពីរក្សាបរិភ័ណ្ឌ ឈឹម-ណាក ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យ ធ្វើការនៅសាលាមន្ទីរកៅល្បីសាវ៉ុត ។

ឃុនមេធមន្ត្រី មាស-យុគ " " ។

បញ្ញាសាគណ គាំ-ឌុំ " " ។

## អស្សរិទ្ធិសុរិន្ទ

ឲកញ៉ា នាយកមន្ត្រី យឿន-ចឹម ក្នុងយពុទ្ធសាសនបណ្ឌិត្យ ។

## មណីសារភ័ណ

លោក សារ-សៀង ជាងគំនូរនៅមន្ទីរកៅល្បីសាវ៉ុត ។

ឃុនមត្តប្រីជា គឹ-គឹមស៊ុរ ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យធ្វើការនៅមន្ទីរកៅល្បីសាវ៉ុត ។

ទស្សនាវដ្ដីកម្ពុជសុរិយា សូមជូនពរសព្ទសាធុការដល់អស់លោកដូចមានកាយនាមខាងលើនេះ សូមឲ្យបានទទួលសេចក្ដីសុខ-ចំរើនជាកំយេព្យាភាពឡើងទៅកុំបើឃ្លាតឡើយ ។

# សេចក្តីរាយការសង្ខេប

## នៃមហាសង្ឃសន្និបាតនៅវត្តព្រះកែវនិងវត្តសាកវ៉ែន

កាលពីថ្ងៃ១១ណូវែម្ប្រ១៩៤៤ វេលាម៉ោង៩កន្លះ មានការប្រជុំធំ អស់ទាំងលោកមេគណ និងអនុគណ ព្រមទាំងសម្តេចសង្ឃនាយកគណមហានិកាយនិងធម្មយុត្តិ ព្រះរាជាគណៈផ្សេងៗនៅក្រុង សឹងបាននិមន្តទៅជួបជុំនៅព្រះវិហារព្រះកែវ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះបរមរាជបិតា, សម្តេចព្រះវររាជជននីនាថ ព្រមទាំងសេនាបតីក្រសួងធម្មការនិងពួកមន្ត្រីក្នុងព្រះរាជសំណាក់ ក៏បានស្តេចយាងទៅនិងអញ្ជើញទៅជួបជុំក្នុងឱកាសនោះផង ។

លុះស្តេចយាងមកដល់មន្ទីរព្រះសុធម្ម ដែលមានគណសង្ឃគង់រង់ចាំនោះហើយ នោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ថ្លែងព្រះរាជឱង្ការអំណរអរគុណនិងសេចក្តីសោមនស្សរបស់ទ្រង់ ចំពោះព្រះសង្ឃដែលបាននិមន្តមកជួបជុំជាមហាសន្និបាត ។ រួចទ្រង់មានព្រះរាជឱង្ការចំពោះគណសង្ឃមហានិកាយថា ទ្រង់មានព្រះរាជហឫទ័យរីករាយណាស់ ដែលព្រះសង្ឃគណៈនេះបានស្រុះស្រួលព្រមព្រៀងប្រតិបត្តិតាមបញ្ញត្តិ ដើម្បីឲ្យកើតសេចក្តីចំរើនដល់ទូលាយទៅអនាគត ទាំងខាងពុទ្ធចក្រនិងអាណាចក្រ ។

តមកសេនាបតីក្រសួងធម្មការបានថ្លែងថា ជាតំណាងតាងនាមលោកឡេស៊ីដង់ស៊ុបេរីយើរ ដល់ព្រះករុណាជាអម្ចាស់ជីវិត និង

គណសង្ឃក្នុងមហាសន្និបាតនោះថា លោកស្តាយណាស់ដែលមិនបាន ឱកាសចូលមកជំនុំ ដោយមានករណីយកិច្ច ហើយលោកបានថ្លែងអំណរអរគុណចំពោះព្រះសង្ឃព្រមទាំងមានសង្ឃមជាព្រះសង្ឃគណ-មហានិកាយនិងព្រមព្រៀងស្រុះស្រួលប្រតិបត្តិតាមបញ្ញត្តិដែលជាហេតុដ៏សំខាន់ក្នុងការដឹកនាំអ្នកកាន់សាសនា ទាំងអ្នកបួស ទាំងគ្រហស្ថឲ្យមានយោបល់ត្រូវនិងប្រតិបត្តិត្រឹមត្រូវតាមច្បាប់វិន័យ ។

លុះដល់ម៉ោង ១១ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ឲ្យចាត់ចែងប្រគេនចង្ហាន់ដល់ព្រះសង្ឃ ដែលបាននិមន្តមកជំនុំមានចំនួនច្រើនជាង ៨០ រូបឡើងទៅ ក្នុងឱកាសនោះផង ។

កាលពីថ្ងៃ ១០ និង ១១ ណូវែម្ប៌ ១៩៤៤ នៅឱកាសដែលចូលទៅថ្វាយបង្គំសម្តេចព្រះសង្ឃនាយកវត្តសាកវ៉ន នោះលោកមេគណដែលនិមន្តមកអំពីតំបន់នានាក្នុងប្រទេស បានប្រជុំគ្នានៅវត្តសាកវ៉នក្រោមអធិបតីនៃសម្តេច ព្រះមហាសុមេធាធិបតីដោយជួបជុំជាមួយនឹងព្រះកថាគណៈទាំងពួង ។

នៅឱកាសប្រជុំទាំងពីរលើកនេះ អ្នកឧកញ៉ាអគ្គមហាសេនាសេនាបតីក្រសួងធម្មការ បានអញ្ជើញទៅជួបជុំជាមួយផងដែរ ។

នៅវេលាប្រជុំនោះ មាននិយាយពន្យល់អំពីក្រមនឹងសង្ឃប្រកាស ជឿនរៀបចំការសាសនាឲ្យបានល្អឡើង ដែលសម្ដេចព្រះសង្ឃនាយក និងសេនាបតីក្រសួងធម្មការបានព្រាងរៀបរៀងឡើង ។

លោកគ្រូព្រះពោធិវង្ស ជួន-ណាត មានថេរដីកាបញ្ជាក់មកទៀត អំពីបំណងរបស់សម្ដេចព្រះសង្ឃនាយក ដើម្បីរំលឹកអស់លោកមេគណ និងអនុគណ អំពីមុខក្រសួងនិងកិច្ចការរបស់ចៅអធិការ ក្នុងការត្រួតត្រាវត្តរបស់ខ្លួនៗ តាមរបៀបដែលសម្ដេចព្រះសង្ឃនាយករៀបចំទុក ។

មុនបិទប្រជុំលើកក្រោយនេះ ព្រះសង្ឃដែលសន្និបាតបាននាំគ្នាសូត្រធម៌ "ជយន្តោ" សុំឲ្យមហានគរបានគង់វង្ស ត្រឡប់មានវឌ្ឍនភាពឡើងវិញដោយឆាប់រហ័ស ។

នៅឱកាសនោះ ព្រះសង្ឃបានសូត្រធម៌ជូនពរសព្ទសាធុការ ដល់លោកនាយកកងនាវា សង់ដឺគូស៍ អធិបតីសហរដ្ឋតណ្ហស៊ុន និងជាភ្នាក់ងារជាន់ខ្ពស់នៅសមុទ្រប៉ាស៊ីហ្វិក , ថ្វាយព្រះសព្ទសាធុការពរ ដល់ព្រះករុណាព្រះបាទសម្ដេចព្រះសីហនុ-វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី និងជូនពរសព្ទសាធុការ ដល់លោកប្រេស៊ីដង់ស៊ីប៊ើហ៊ើរ នាយកក៏ដការអាណាព្យាបាល សូមឲ្យទ្រង់ព្រះករុណាជាម្ចាស់ជីវិត និងអស់លោកឲ្យបានប្រកបដោយពរគឺ: អាយុ: វណ្ណ: សុខ: ពល: តរៀងទៅ ។

# អំពីចៅអធិការដែលទើបតាំងថ្មី

ក្នុងរវាងខែសេបតេមប្រ៊ី – អុកតូប្រ៊ី ១៩៥៥

១ – សញ្ញាប័ត្រលេខ ៩៩ ចុះថ្ងៃ ២២-៩-៥៥ តាំងលោកគ្រូ គឹម-នៃត កើតឆ្នាំច អាយុ ៣៩ វស្សា ១៣ នាមធាយា បញ្ញាថេរ ជាចៅអធិការវត្តអង្គជ័យ ឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ ។

២ – សញ្ញាប័ត្រលេខ ១០០ ចុះថ្ងៃ ២២-៩-៥៥ តាំងលោកគ្រូ ថៃន ហម កើតឆ្នាំថោះ អាយុ ៥៥ វស្សា ៣២ នាមធាយា សុវណ្ណបញ្ញា ជាចៅអធិការវត្តឃោសពាម ឃុំកមអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវ ។

៣ – សញ្ញាប័ត្រលេខ ១០១ ចុះថ្ងៃ ២២-៩-៥៥ តាំងលោកគ្រូ នឹម-ហម កើតឆ្នាំខាល អាយុ ៣២ វស្សា ១២ នាមធាយា ព្រហ្មជោត-ត្ថេរ ជាចៅអធិការវត្តអង្គនោម ឃុំកមអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវ ។

៤ – សញ្ញាប័ត្រលេខ ១០២ ចុះថ្ងៃ ២៩-៩-៥៥ តាំងលោកគ្រូខេត-បេស កើតឆ្នាំម្សាញ់ អាយុ ២៩ វស្សា ៧ នាមធាយា សុវណ្ណ-បញ្ញា ជាចៅអធិការវត្តពោធិ៍អង្គជុំ ឃុំកមអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវ ។

៥ – សញ្ញាប័ត្រលេខ ១០៣ ចុះថ្ងៃ ២៩-៩-៥៥ តាំងលោកគ្រូអ៊ុំ-ឡុង កើតឆ្នាំខាល អាយុ ៥៥ វស្សា ៣៤ នាមធាយា សុវណ្ណ-ត្ថេរ ជាចៅអធិការវត្តគោកគោ ឃុំកមអណ្ដើក ស្រុកគិរីវង្ស តាកែវ ។

៦ – សញ្ញាប័ត្រលេខ ១០៤ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូឈិម-ហ៊ឹម កើតឆ្នាំជូត អាយុ ៣២ វស្សា ១១ នាមធាយា ឯកេត្តបញ្ញា ជាចៅអធិការវត្តព្រៃវែង ឃុំកំពែង ស្រុកគីរីវង្ស (តាកែវ) ។

៧ – សញ្ញាប័ត្រលេខ ១០៥ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូជៃ-នុត កើតឆ្នាំខាល អាយុ ៤៤ វស្សា ១៣ នាមធាយា ឯកត្តេបញ្ញោ ជាចៅអធិការវត្តអាងស្វាយក្រោម ឃុំកំពែង ស្រុកគីរីវង្ស (តាកែវ) ។

៨ – សញ្ញាប័ត្រលេខ ១០៦ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូអ៊ុក-ជឹម កើតឆ្នាំមមែ អាយុ ៣៨ វស្សា ១៦ នាមធាយា ព្រហ្មបញ្ញោ ជាចៅអធិការវត្តពែង ឃុំកំពែង ស្រុកគីរីវង្ស (តាកែវ) ។

៩ – សញ្ញាប័ត្រលេខ ១០៧ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូគង់-ស៊ុំ កើតឆ្នាំរកា អាយុ ៣៦ វស្សា ១៥ នាមធាយា ព្រហ្មកេត្តោ ជាចៅអធិការ វត្តសរសៃ ឃុំអង្គញ់ ស្រុកត្រាំង (តាកែវ) ។

១០ សញ្ញាប័ត្រលេខ ១០៨ ចុះថ្ងៃ ២៦-១០-៤៤ តាំងលោកគ្រូ មាស-ធានី កើតឆ្នាំថោះ អាយុ ៤២ វស្សា ២២ នាមធាយា អាកស្សរក ជាចៅអធិការ វត្តតាទេកឃុំពួក ស្រុកពួក សៀមរាប ។

ឯកភាគមិលិន្ទបញ្ហា

ហ្លួងនិពន្ធមន្ត្រី ញ៉ុក ថែម ប្រែនិងរៀបរៀង

(តមក)

## អង្គ ៤ របស់គោ:

១- មិនលះបង់ពេលក្រោល ដែលខ្លួនធ្លាប់នៅ ។

២- លីតែនឹម អូសទាញតែនឹមទៅ ទុកជាធ្ងន់ក៏ដោយ ស្រាលក៏ដោយ ។

៣- ប្រើធ្មេញទំពាអៀងស្មៅ ឆ្អែតហើយក៏ផឹកទឹក ។

៤- កាលម្ចាស់បង្ហាត់ឲ្យធ្វើយ៉ាងណាៗ ក៏ធ្វើតាមពាក្យគ្រប់យ៉ាង ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៤ ប្រការគឺ :

១- មិនលះបង់ពេលឱកាសរបស់ខ្លួន ឧស្សាហ៍ពិចារណារឿយៗ ថា កាយនេះមិនទៀងទេ មានការបែកធ្លាយខ្ទាត់ខ្ទាយចេញទៅជាធម្មតា ។

២- សមាទានព្រហ្មចរិយធម៌ ប្រព្រឹត្តព្រហ្មចរិយឲ្យបរិសុទ្ធិដូរផង់ ដរាបដល់អស់ជីវិត ប្រកបដោយសុខខ្លះ ទុក្ខខ្លះក្នុងខណៈផ្សេងៗគ្នា ។

៣— ទទួលយកឱវាទានុសាសន៍របស់ឧបជ្ឈាយ៍អាចារ្យដោយពេញចិត្តជ្រះថ្លានឹងតាំងចិត្តស្តាប់ធម៌ ។

៤— តាំងចិត្តទទួលយកឱវាទានុសាសន៍របស់កល្យាណជនគ្រប់ជាន់គ្រប់ថ្នាក់ ទាំងជាថេរៈ មជ្ឈិមៈ ឬនវកៈ ទាំងជាគ្រហស្ថដែលជាពួកឧបាសកឧបាសិកា ។

## អង្គ ៤ របស់ព្រានព្រៃ

១– កាលចេញទៅស្វែងរកនេសាទសត្វព្រៃ មិនមានងងុយដេក ។

២– តាំងចិត្តទុកតែក្នុងការនេសាទសត្វព្រៃប៉ុណ្ណោះ ។

៣– ដឹងកាលវេលាក្នុងការនេសាទសត្វព្រៃ ។

៤– ឃើញសត្វព្រៃហើយក៏កើតចិត្តត្រេកអរដ៏ក្រៃលែង ថា នឹងបានសត្វព្រៃនោះមក ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៤ ប្រការគឺ:

១– ប្រាសចាកថីនមិទ្ធៈ គឺមិនមានចិត្តស្រពោន ស្រពន់ងោកងក់ ។

២– ចងចិត្តទុកក្នុងអារម្មណ៍តែមួយ ដែលអាចឲ្យលុះបានធម៌វិសេសដ៏ទៀងទាត់ ។

៣- ដឹងកាលនឹងចំរើនសមាធិ នឹងកាលដែលចេញចាកសមាធិ ។

៤– ដូចប្រទះនឹងអារម្មណ៍ជាទីរីករាយហើយ ក៏កើតសេចក្ដីសប្បាយចិត្តថានឹងបានសម្រេចគុណវិសេសដ៏ក្រៃលែងឡើងទៅទៀត ។

## អង្គ ៤ របស់នាយខ្មាន់ធ្នូ

១– កាលនឹងបាញ់កូនសរទៅ ក៏ទប់ជើងឲ្យជាប់នឹងផ្ទៃផែនដី តាំងជង្គង់ជង្គង់ឲ្យនឹងមិនឲ្យកម្រើកញ័រ លើកដងធ្នូឡើងតាំងស្មើនឹងត្រចៀក

ស្រលៀនកែ្អកបូញមាត់សំដៅឲ្យត្រង់ទៅ ទើបកើតចិត្តថានឹងបាញ់ទៅ ។

២- ថែរក្សាឈើដំពាមទុក សម្រាប់ពត់កូនសរដែលវៀចកោងឬនឲ្យត្រង់បាន ។

៣- សំឡឹងផ្ចង់ឲ្យចំទៅទីលំនៅ ។

៤- ហាត់បាញ់ទាំងក្នុងវេលាព្រឹកទាំងក្នុងវេលាល្ងាច ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គ ៤ ប្រការ គឺ:

១- តាំងខប់ជើងគឺវីរិយៈ (សេចក្ដីព្យាយាម) ទុកលើផែនដីគឺសីលឲ្យខ្ជាប់ បំពេញវត្តនិងសោរច្ចៈមិនឲ្យទ្រេតទ្រោត ដំកល់ចិត្តទុកក្នុងសំវរៈ (សេចក្ដីសង្រួម) កំចាត់បង់នូវទោមនស្សនិងសោមនស្សផ្ញើយោនិសោមនសិការៈទុកក្នុងចិត្ត ផ្គូផ្គងសេចក្ដីព្យាយាម បិទទ្វារទាំង ៦ ដំកល់ស្មារតីឲ្យខ្ជាប់ ញុំាងសេចក្ដីរកយឲ្យកើតឡើង ថាអញនឹងសម្លាប់កងកិលេសដោយញាណគឺកូនសរ ។

២- ចំរើនសតិបដ្ឋានដូចនាយខ្មាន់ធ្នូ ថែរក្សាឈើដំពាមទុក ពត់ចិត្តដែលវៀចកោងឲ្យត្រង់ល្អ ។

៣- ពិចារណាកាយនេះ តាមផ្លូវព្រះត្រៃលក្ខណ៍ ។

៤- ដំកល់ចិត្តទុកក្នុងអារម្មណ៍ ១ សព្វាហ៍ពិចារណារាល់ពេលព្រឹកពេលល្ងាច ។ (មានត)

# សេចក្តីជូនដំណឹង

ពុទ្ធសាសនបណ្ឌិត្យសូមជូនដំណឹង ដល់អស់លោក-អ្នកជាវទស្សនាវដ្តី កម្ពុជសុរិយា សូមជ្រាប ។

ឥឡូវដល់វេលាផុតឆ្នាំចាស់ (ឆ្នាំ១៩៦៦) ចូលមកក្នុងឆ្នាំថ្មី (ឆ្នាំ១៩៦៧)ហើយ ពុទ្ធសាសនបណ្ឌិត្យ សូមរំលឹកអស់លោក-អ្នកជាវទស្សនាវដ្តីនេះ ទាំងអ្នកជាវចាស់ទាំងអ្នកជាវថ្មី បើអស់លោក-អ្នកត្រូវការទស្សនាវដ្តី ឆ្នាំ ១៩៦៧ សូមមេត្តាចុះឈ្មោះ-ទីលំនៅ-ដំឡៃជាវ ផ្ញើទៅពុទ្ធសាសនបណ្ឌិត្យជាប្រញាប់កុំបីខាន ដើម្បីជាឱកាសឲ្យពុទ្ធសាសនបណ្ឌិត្យ ចាត់ការផ្ញើសៀវភៅមកជូនអស់លោក-អ្នកតាមកាលវេលា ។

ដូច្នេះ សូមអស់លោក-អ្នកជាវទាំងឡាយ កុំបីបង្អែបង្អង់ឡើយ ដើម្បីនាំគ្នាជួយកសាងអក្សរសាស្ត្ររបស់ជាតិ ឲ្យបានចំរើនរុងរឿងទាន់កាលសម័យដូចជាប្រទេសជិតខាងឡើង ។